ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការប្រើប្រាស់ដីនៅក្នុងឃុំអណ្តូងថ្ម

## ស្រុកព្រៃនប់ ខេត្តព្រះសីហនុ





រៀបចំដោយ : គណៈកម្មាធិការកសាងផែនការ និងថវិកា និងក្រុមប្រឹក្សាឃុំ

គាំទ្របច្ចេកទេសដោយ : សមាសភាគរៀបចំដែនដី/ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

គាំទ្រមូលនិធិដោយ :អង្គការ DANIDA-DFIT-NZAid

ឆ្នាំ២០០៩

# មាតិកា


អារម្ភកថា ........................................ ១

សេចក្តីផ្តើម ........................................ ២

ជំពូក១ ព័ត៌មាន និងទិន្នន័យសំរាប់កសាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ........................................ ៣

១.១ ស្ថានភាពទូទៅ ........................................ ៣

១.១.១ ទីតាំងរដ្ឋបាល ........................................ ៣

១.១.២ ប្រជាសាស្ត្រ ........................................ ៥

១.១.៣ ភាពគ្មានដីធ្លី ........................................ ៦

១.១.៤ ស្ថានភាពសេដ្ឋកិច្ច ........................................ ៧

១.១.៥ ស្ថានភាពអប់រំ និងសិក្សាធិការ ........................................ ៩

១.១.៦ ស្ថានភាពសុខាភិបាល ........................................ ១០

១.១.៦.១ ផ្នែកសុខាភិបាល ........................................ ១០

១.១.៦.២ ការផ្គត់ផ្គង់ទឹកស្អាត ........................................ ១១

១.២ ស្ថានភាពភូមិសាស្ត្រ ........................................ ១២

១.២.១ ទីតាំងភូមិសាស្ត្រ ........................................ ១២

១.២.២ អាកាសធាតុ ........................................ ១៣

១.២.៣ ហេដ្ឋារចនាសម្ព័ន្ធ ........................................ ១៦

១.៣ ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន ........................................ ១៨

១.៣.១ ស្ថានភាពនៃការប្រើប្រាស់ដី ........................................ ១៨

១.៣.២ ស្ថានភាពនៃការកាន់កាប់ដី ........................................ ២២

១.៣.៣ ផលិតកម្មកសិកម្ម ........................................ ២២

១.៣.៤ ធនធានធម្មជាតិ ........................................ ២៧

១.៣.៤.១ ធនធានព្រៃឈើ ........................................ ២៧

១.៣.៤.២ ធនធានជលផល ........................................ ២៨

១.៤ ទីផ្សារ និងខ្សែចង្វាក់ផលិតផល ........................................ ២៩

១.៤.១ ទីផ្សារ និងតម្លៃកសិផល ផលអនុផលព្រៃឈើ និងផលនេសាទ ........................................ ២៩

១.៤.២ ខ្សែសង្វាក់ និងចរាចរផលិតផល ........................................ ៣០

១.៤.៣ ឱកាស និងឧបសគ្គ ........................................ ៣១

ជំពូក២ ការវិភាគពីឧបស័គ្គ តម្រូវការសំរាប់អនាគត និងសក្តានុពល ........................................... ៣២
២.១ តំបន់រសើប .............................................................................................. ៣២
២.២ ការប្រឈម / ឧបស័គ្គ ................................................................................... ៣២
២.៣ កំណត់តម្រូវការនៃការអភិវឌ្ឍន៏ និងគោលដៅយុទ្ធសាស្ត្រឃុំ .......................................... ៣៣
២.៤ តម្រូវការសំរាប់អនាគត ................................................................................ ៣៣
២.៤.១ ប្រជាសាស្ត្រ ............................................................................................ ៣៣
២.៤.១.១ អត្រាកំណើន ......................................................................................... ៣៣
២.៤.១.២ ការធ្វើចំណោលប្រជាសាស្ត្រ ......................................................................... ៣៤
២.៤.២ តម្រូវការដីសំរាប់លំនៅដ្ឋាន ........................................................................... ៣៤
២.៤.៣ តម្រូវការដីសំរាប់កសិកម្ម ............................................................................. ៣៤
២.៤.៤ តម្រូវការសំរាប់កិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ........................................... ៣៤
២.៤.៥ តម្រូវការដីសំរាប់ ហេដ្ឋារចនាសម្ព័ន្ធ ................................................................ ៣៦
២.៤.៥.១ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងប្រព័ន្ធសង្គម .................................................. ៣៦
២.៤.៥.២ តម្រូវការដីសាលារៀន ............................................................................... ៣៨
២.៤.៥.៣ សេវាកម្មសុខភាព និងការផ្គត់ផ្គង់ទឹកស្អាត ....................................................... ៣៩
ជំពូក៣ ផែនការប្រើប្រាស់ដីពេលអនាគត ................................................................... ៤០
៣.១ ស្ថានភាពដី សក្តានុពលដី និងតម្រូវការដី ............................................................... ៤០
៣.១.១ ស្ថានភាពដីទូទៅ និងសក្តានុពល ..................................................................... ៤០
៣.១.២ តម្រូវការដីតាមប្រភេទ ................................................................................ ៤០
៣.២ ការបែងចែកដីតាមតម្រូវការប្រើប្រាស់ .................................................................. ៤១
៣.២.១ ការវិភាគអន្តរះអំពើ .................................................................................... ៤១
៣.២.២ ផែនទីប្រើប្រាស់ដីអនាគត ............................................................................. ៤១
៣.២.៣ ការបរិយាយការប្រើប្រាស់តាមក្បាលដី ............................................................. ៤២

ឧបសម្ព័ន្ធ១ : ការពិពណ៌នាអំពី ស្ថានភាពការប្រើប្រាស់ដីបច្ចុប្បន្ន

ឧបសម្ព័ន្ធ២ : ស្ថានភាពនៃការគ្រប់គ្រងនិងកាន់កាប់ដីបច្ចុប្បន្ន

ឧបសម្ព័ន៣ : បញ្ហាពាក់ព័ន្ធក្នុងការប្រើប្រាស់ដី

ឧបសម្ព័ន៤ : ក្របខ័ណ្ឌអភិវឌ្ឍន៍

ឧបសម្ព័ន៥ : បញ្ជីគំរោង

ឧបសម្ព័ន៦ : ផែនទីប្រើប្រាស់ដីលំអិត

ឧបសម្ព័ន៧ : ផែនទីប្រើប្រាស់ដីសាមញ្ញ

ឧបសម្ព័ន៨ : ផែនទីប្រើប្រាស់ដីពេលអនាគត ឆ្នាំ២០០៩-២០២២

# អារម្ភកថា

របាយការណ៍ស្តីអំពីផែនការប្រើប្រាស់ដីនៅក្នុង**ឃុំអណ្តូងថ្ម**ខេត្តព្រះសីហនុរយៈពេល១៥ឆ្នាំ ត្រូវបានរៀបចំឡើងដោយក្រុមប្រឹក្សា**ឃុំអណ្តូងថ្ម** និងមានការចូលរួមពីគណៈកម្មាធិការកសាងផែនការនិងថវិកានិងប្រជាពលរដ្ឋគ្រប់ស្រទាប់ក្រោមកិច្ចសម្របសម្រួលពីក្រុមសម្របសម្រួលផែនការប្រើប្រាស់ដីស្រុកព្រៃនប់(D_LUP) ពីក្រុមសំរបសំរួលផែនការប្រើប្រាស់ដី**ខេត្តព្រះសីហនុ**(P_LUP) និងក្រុមការងាររបស់សមាសភាគរៀបចំដែនដី ( Land Management Component) របស់អគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម នៃក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ។

គោលបំណងចំបងនៃផែនការប្រើប្រាស់ដីនៅក្នុង**ឃុំអណ្តូងថ្ម**នេះ ជាត្រីវិស័យតំរង់ទិសដល់ការអភិវឌ្ឍន៍ និងដើម្បីគាំទ្រដល់ដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ និងកម្មវិធីវិនិយោគឃុំសង្កាត់ទាំងមូលអោយចំទិសដៅតំរូវការរបស់ប្រជាពលរដ្ឋ ស្របតាមគោលនយោបាយកាត់បន្ថយភាពក្រីក្រ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ សំដៅពង្រឹងអភិបាលកិច្ចល្អរបស់រាជរដ្ឋាភិបាលដើម្បីលើកស្ទួយសេដ្ឋកិច្ចនិងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងសង្កាត់ ឱ្យកាន់តែប្រសើរឡើង ។

ក្នុងនាមក្រុមប្រឹក្សាសង្កាត់អាណត្តិទី២ សូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅដល់គណៈកម្មាធិការកសាងផែនការនិងថវិកា ជនបង្គោលផែនការប្រើប្រាស់ដីនិងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមក្នុងដំណើរការរៀបចំផែនការប្រើប្រាស់ដីនេះតាំងពីដើមដល់ចប់ ។ ជាមួយគ្នានេះ ក៏សូមថ្លែងអំណរគុណផងដែរ ដល់ក្រុមការងាររបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី**ខេត្តព្រះសីហនុ** ព្រមជាមួយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ដែលបានជួយសម្របសម្រួលការងារនេះជាមួយអាជ្ញាធរមូលដ្ឋាន មន្ទីរអង្គភាពពាក់ព័ន្ធនៅគ្រប់លំដាប់ថ្នាក់ ។លើសពីនេះទៀតក៏សូមថ្លែងអំណរគុណជាពិសេសដល់អង្គការDANIDA/DFID-NZAidដែលបានផ្តល់ជំនួយឥតសំណងសំរាប់ដំណើរការរៀបចំផែនការប្រើប្រាស់ដីនេះចាប់តាំងពីការចាប់ផ្តើមរហូតដល់ទីបញ្ចប់ ។

យើងខ្ញុំទាំងអស់គ្នាសង្ឃឹមថាសម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់នឹងបានយល់ដឹងអំពីស្ថានភាព និងតម្រូវការព្រមទាំងបញ្ហាប្រឈមទាំងឡាយពាក់ព័ន្ធនឹងការប្រើប្រាស់ដីដែលរាំងស្ទះ ដល់ដំណើរការអភិវឌ្ឍ**ឃុំអណ្តូងថ្ម** ហើយនឹងបង្ហាញនូវទឹកចិត្តសម្បុរសធមិដ៏ថ្លៃថ្លាតាមរយៈការចូលរួមផ្តល់នូវសំភារៈនិងថវិកាសំរាប់គាំទ្រការអនុវត្តន៍ផែនការប្រើប្រាស់ដីនេះ ដើម្បីចូលរួមចំណែកអភិវឌ្ឍន៍មូលដ្ឋានតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ របស់រាជរដ្ឋាភិបាលប្រកបដោយជោគជ័យ ។

ធ្វើនៅថ្ងៃទី...០៨...ខែ............ឆ្នាំ ២០០៩

**ឃុំអណ្តូងថ្ម**

ទ៊ាន់_ណា

# <u>សេចក្តីផ្តើម</u>

**អណ្តូងថ្ម** គឺជាឃុំមួយសម្បូរទៅដោយធនធានធម្មជាតិដូចជា ព្រៃភ្នំ ដៃព្រែក ព្រៃកោងកាង ធនធានជលផលសមុទ្រនិងវាលស្រែសំរាប់ប្រកបរបរកសិកម្ម ។ ដោយសារមានវិសាលភាពនៃផ្ទៃដីកសិកម្ម ហេតុនេះប្រជាពលរដ្ឋប្រមាណ៨៦%ប្រកបរបរកសិកម្មរួមមាន ការធ្វើស្រែ ចំការ ដាំដំណាំរួមផ្សំ និងការចិញ្ចឹមសត្វ (ស្ថានភាពឃុំឆ្នាំ២០០៩) ។ ក្រៅពីមុខរបរកសិកម្មប្រជាពលរដ្ឋនៅទីនេះប្រកបមុខរបរផ្សេងទៀតដូចជា នេសាទ ការឡើងភ្នំ ស៊ីឈ្នួលកំលាំងពលកម្ម និង លក់ដូរ ។

ក្នុងស្ថានភាពសព្វថ្ងៃនេះ ប្រជាពលរដ្ឋជួបប្រទះនូវបញ្ហាប្រឈមដូចជា ខ្វះមុខរបរបន្ថែម ការអប់រំនៅមូលដ្ឋាននៅមានកំរិត សេដ្ឋកិច្ចប្រចាំគ្រួសារពឹងផ្អែកជាសំខាន់ទៅលើតែដំណាំស្រូវតែប៉ុណ្ណោះ មិនទាន់មានប្រព័ន្ធទឹកស្អាតហេដ្ឋារចនាសម្ព័ន្ធរូបវន្តមិនទាន់គ្រប់គ្រាន់សំរាប់បំពេញសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ។ ដោយឡែកចំពោះការប្រើប្រាស់ដីធ្លីនៅមិនទាន់មានលក្ខណៈសមស្រប ព្រោះនៅទីតាំងមួយចំនួនប្រជាពលរដ្ឋបានរក្សាទុកដីនៅទំនេរដោយមិនបានបង្កបង្កើនផលដែលជាកត្តាមួយគំរាមកំហែងដល់សន្តិសុខស្បៀងពេលបច្ចុប្បន្ន និងអនាគត ។

ម្យ៉ាងវិញទៀតការប្រើប្រាស់ដីត្រូវបានសង្កេតឃើញថា មានបញ្ហាគួរឱ្យព្រួយបារម្ភ និងត្រូវដោះស្រាយជាបន្ទាន់ ។ បញ្ហាទាំងនេះមានដូចជាទំនាស់ព្រំប្រទល់ដីធ្លីរវាងប្រជាពលរដ្ឋនិងប្រជាពលរដ្ឋទំនាស់ព្រំប្រទល់រវាងឃុំនិងឃុំដោយសារអាជ្ញាធរមិនឯកភាពគ្នាទៅលើព្រំប្រទល់រដ្ឋបាលរៀង១ខ្លួន ជាក់ស្តែងឃុំ សង្កាត់ខ្លះគ្រប់គ្រងហួសដែនសមត្ថកិច្ចដែលក្រសួងមហាផ្ទៃបានកំណត់ ដែលធ្វើឱ្យឃុំបាត់បង់ដែនគ្រប់គ្រងមិនយល់ព្រម និងធ្វើការទាមទារឱ្យមានការដោះស្រាយ ។

ដោយឡែកចំពោះធនធានធម្មជាតិបាននឹងកំពុងទទួលរងការគំរាមកំហែងដូចជា ការរុករានតំបន់ព្រៃបៃតងដើម្បីយកដីធ្វើចំការធ្វើឡធ្យូងកាប់អុសលក់ការបរបាញ់សត្វព្រៃសំរាប់ធ្វើអាជីវកម្ម និងការកាប់រានដីធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួនសំរាប់លក់ដូរ ។ ជាងនេះទៅទៀតដោយសារកំណើនប្រជាពលរដ្ឋ នៅតាមឆ្នេរធ្វើអោយព្រៃកោងកាងមួយចំនួនត្រូវបានកាប់បំផ្លាញសំរាប់សង់លំនៅដ្ឋាន ការធ្វើវារីវប្បកម្មចិញ្ចឹមថ្មត្រីការធ្វើអ៊ូរជួសជុលទូកនេសាទនិងការកាប់ដើមកោងកាង សំរាប់ប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ និងលក់ដូរបន្តិចបន្តួច ។

ការប្រឈមនឹងបញ្ហាដែលបានលើកឡើងខាងលើ ជាឧបសគ្គរាំងស្ទះដល់ដំណើរការអភិវឌ្ឍន៍ហេតុនេះការរៀបចំផែនការប្រើប្រាស់ដីជាភារកិច្ចដ៏ចាំបាច់និងបន្ទាន់ ធ្វើយ៉ាងណាឱ្យផែនការនោះបង្កភាពងាយស្រួលក្នុងការប្រើប្រាស់ដីទៅតាមលក្ខណៈបច្ចេកទេស វិទ្យាសាស្ត្រនិងសមស្របទៅនឹងតំរូវការរបស់ប្រជាជន ។ ដើម្បីរៀបចំផែនការប្រើប្រាស់ដីឱ្យបានសមស្របទៅតាមលក្ខណៈបច្ចេកទេស ក្រុមCLUPបានសហការជាមួយក្រុមប្រឹក្សាឃុំ មេភូមិនិងប្រជាពលរដ្ឋក្នុងការកសាងផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់ និងកម្មវិធីវិនិយោគឃុំ/សង្កាត់ ។

## ជំពូក១

## ព័ត៌មាន និង ទិន្នន័យសម្រាប់កសាងផែនការប្រើប្រាស់ដីនៅឃុំអណ្តូងថ្ម

### ១.១ ស្ថានភាពទូទៅ

មុនថ្ងៃ៧ មករា ឆ្នាំ១៩៧៩ ឃុំអណ្តូងថ្មគឺជា ភូមិមួយរបស់ឃុំសំរុងតែប៉ុណ្ណោះ ។ ប៉ុន្តែចាប់ពីថ្ងៃរំដោះពីរបបប៉ុលពតមក ប្រទេសជាតិជួបបញ្ហាសង្គ្រាមស៊ីវិល ការគ្រប់គ្រងឃុំដែលមានផ្ទៃដីធំជួបការលំបាក ហេតុនេះទើបរដ្ឋាភិបាលបានរៀបចំរចនាសម្ព័ន្ធភូមិឃុំឡើងវិញ ដោយកាត់ភូមិអណ្តូងថ្មទួលទទឹងព្រៃនប់អូរឧកញ៉ាហេងមកជាឃុំមួយៗវិញ ។ ចាប់ពីពេលនោះមកភូមិអណ្តូងថ្មបានក្លាយទៅជាឃុំអណ្តូងថ្ម ។ បើតាមការរៀបរាប់របស់ ចាស់ព្រឹទ្ធាចារ្យក្នុងឃុំបានឱ្យដឹងថា**អណ្តូងថ្ម**គឺជាឈ្មោះដែលប្រជាពលរដ្ឋសន្មត់ឱ្យទៅតាមអណ្តូងបូរាណមួយដែលមានអាយុប្រមាណជាង ១៥០ឆ្នាំមកហើយ ។ សព្វថ្ងៃអណ្តូងនោះស្ថិតនៅខាងកើតវត្តមុន្នីសាលព្រឹក្សចំងាយប្រមាណ៥០មអាស្រ័យហេតុនេះបានជាប្រជាពលរដ្ឋហៅឃុំនេះថា ឃុំអណ្តូងថ្ម ។



#### ១.១.១ ទីតាំងរដ្ឋបាល

| | | |
|---|---|---|
| ខេត្ត | ខេត្តព្រះសីហនុ | |
| ស្រុក/ខណ្ឌ | ស្រុកព្រៃនប់ | |
| ឃុំ/សង្កាត់ | ឈ្មោះ: ឃុំអណ្តូងថ្ម | លេខកូដ: ១៨០២០១ |
| ចំនួន ភូមិ | មាន០៥ភូមិ ( ភូមិអណ្តូងថ្ម ត្រពាំងស្គុយ-១ ត្រពាំងស្គុយ-២ អូរត្រាវ និងបន្ទាយប្រិយ៍) | |

អណ្តូងថ្មគឺជាឃុំមួយក្នុងចំណោមឃុំទាំង១៤នៃស្រុកព្រៃនប់ខេត្តព្រះសីហនុមានទីតាំងស្ថិតនៅអមសងខាងតាមបណ្តោយផ្លូវជាតិលេខ៤ សាលាឃុំនេះមានចំងាយប្រមាណ៦គ.មពីសាលាស្រុកព្រៃនប់ ។

ឃុំអណ្តូងថ្មមានព្រំប្រទល់ :

- ខាងជើងទល់នឹងឃុំសំរុង
- ខាងត្បូងទល់នឹងឃុំទួលទទឹង
- ខាងកើតទល់នឹងឆកវាលរេញ
- ខាងលិចទល់នឹង ឃុំអូរត្រេះ និង ឃុំទំនប់រលក ស្រុកស្ទឹងហាវ ។

យោងតាមឯកសារព័តិមានស្ថានភាពឃុំ ឆ្នាំ២០០៩ ឃុំមានផ្ទៃដីសរុបប្រមាណ ៤.៨៩៤,៨២១ហិកតា ( ប្រភព : GIS) ឬ ៥០៥៥ហិកតា (ទិន្នន័យឃុំ) ដែលមានភូមិចំនួន៩ និងក្រុមចំនួន៥៤ ។



## ១.១.២ ប្រជាសាស្ត្រ

ឃុំអណ្តូងថ្មមានប្រជាជនសរុប ចំនួន១.០២៨គ្រួសារ ត្រូវជា៥.៤៥៨នាក់ ក្នុងនោះស្រី២.៧៤១នាក់។ ស្រីមេម៉ាយ ជាមេគ្រួសារមានចំនួន ១៣៩គ្រួសារ និងជនពិការជាមេគ្រួសារមាន ចំនួន ២០ គ្រួសារ ។

**ក . ស្ថិតិប្រជាជន ឃុំអណ្តូងថ្មឆ្នាំ២០០៨តាមក្រុមអាយុ**

| ស្ថិតិតាមក្រុមអាយុ | ប្រុស | ស្រី | សរុប | ផ្សេងៗ |
|---|---|---|---|---|
| អាយុក្រោម០៥ ឆ្នាំ | ៣៣៦ | ៣២៤ | ៦៦០ | |
| អាយុ ០៥ឆ្នាំ | ១៣៥ | ១២២ | ២៥៧ | អាយុចូលរៀនមត្តេយ្យ |
| អាយុពី ៦-១១ឆ្នាំ | ៤១៧ | ៣៩៣ | ៨១០ | អាយុចូលរៀនបឋមសិក្សា |
| អាយុពី ១២-១៤ឆ្នាំ | ២៤៣ | ២៣០ | ៤៧៣ | អាយុចូលរៀនអនុវិទ្យាល័យ |
| អាយុពី ១៥-១៧ឆ្នាំ | ២២៣ | ១៩៨ | ៤២១ | អាយុចូលរៀនវិទ្យាល័យ |
| អាយុពី ១៨-២៤ឆ្នាំ | ៣៦៤ | ៣៧២ | ៧៣៦ | អាយុចូលរៀនមហាវិទ្យាល័យ |
| អាយុពី ២៥-៦០ឆ្នាំ | ៨៤៤ | ៩១៦ | ១៧៦០ | អាយុពេញពលកម្ម |
| អាយុពី ៦១ឆ្នាំឡើងទៅ | ១៥៥ | ១៨៦ | ៣៤១ | អាយុចូលនិវត្តន៏ |
| ប្រជាជនសរុប | **២៧១៧** | **២៧៤១** | **៥៤៥៨** | |
| ចំនួនគ្រួសារសរុប | ១០២៨ | | | |
| ទំហំគ្រួសារមធ្យម | **៥ នាក់/គ្រួសារ** | | | |

**តារាងអត្រាកំណើនមធ្យម**( កំណើនធម្មជាតិ)

| ចំនួនគ្រួសារ/ប្រជាជន | ចំនួនគ្រួសារ/ប្រជាជនតាមឆ្នាំ | | | | កំណើនប្រជាសាស្ត្រ | |
|---|---|---|---|---|---|---|
| | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | កំណើនមធ្យម | កំណើន/ឆ្នាំ |
| ចំនួនគ្រសារសរុប | **៩៣៧** | **១០២៤** | **១០២១** | **១០២៨** | - | - |
| អត្រាកំណើនគ្រួសារ | | ៩% | ០% | ១% | **៣%** | **៣១គ្រួសារ** |
| ចំនួនប្រជាជនសរុប | **៥៣២៨** | **៥៣៨៣** | **៥៤៣៩** | **៥៤៥៨** | - | - |
| អត្រាកំណើនប្រជាជន | | ១% | ១% | ០% | **១%** | **៥៥នាក់** |

**ខ . ដង់ស៊ីតេប្រជាជន**

- គិតជារួម ដង់ស៊ីតេប្រជាជន គឺ ១០៧ នាក់/គីឡូម៉ែត្រក្រឡា ( ៥០៥៥ហ.ក បានពីសង្កាត់ )។
- គិតជារួម ដង់ស៊ីតេប្រជាជន គឺ ១១១ នាក់/គីឡូម៉ែត្រក្រឡា ( ៤.៨៩៤.៨២១ហិកតា )។

**គ. ជនជាតិ :** នៅឃុំអណ្តូងថ្ម មានជនជាតិខ្មែរឥស្លាម ចំនួន៣៦៩គ្រួសារ ត្រូវជា១.៩១១ នាក់។

### ឃ. ជំនឿសាសនា ប្រពៃណី ទំនៀមទំលាប់

នៅឃុំអណ្ដូងថ្មមានប្រជាពលរដ្ឋប្រមាណ៨០%កាន់សាសនាព្រះពុទ្ធ១៩%កាន់សាសនាឥស្លាម និង១%កាន់សាសនាគ្រីស្ត និងមាន វត្ត, ព្រះវិហារយេស៊ូ និងវិហារអ៊ីស្លាម(សាវ៉ាវ) សំរាប់ជាទីកន្លែងប្រតិបត្តិ :

១. វត្ត : មានវត្តមួយកន្លែង ឈ្មោះមុន្នីសាលព្រឹក្ស ដែលមាន ព្រះសង្ឃចំនួន២៩អង្គ យាយជី៦នាក់ តាជី៦នាក់ (កុដិ៣ សាលាបាលី១ សាលាឆាន់១)។

២. វិហារឥស្លាម : វិហារ ២ ។

៣. វិហារយេស៊ូ : ១ ។

អ្នកកាន់សាសនាព្រះពុទ្ធភាគច្រើនការប្រតិបត្តិលាយឡំជាមួយព្រហ្មញ្ញសាសានាដូចជាការសែនព្រេន គោរពអ្នកតា ជាដើម ។ល។

ចំពោះអ្នកកាន់សាសនាឥស្លាមវិញ គេមិនបរិភោគសាច់ជ្រូក សាច់ឆ្កែ ហើយពេលរៀបអាពាហ៍ពិពាហ៍ គេមិនប្រគុំតន្រ្តីឬពិសារគ្រឿងស្រវឹង។

ចំណែកអ្នកកាន់សាសនាយេស៊ូគ្រីស្ទវិញ គោរពព្រះយេស៊ូដែលមានឈើឆ្កាងជានិមិត្តរូប និងពេលរៀបអាពាហ៍ពិពាហ៍គេចូលព្រះវិហារ។

**អត្រាជំនឿសាសនា-វត្តវិហារ និងបុព្វជិត**

| ជំនឿសាសនា | ភាគរយ | ចំនួនវត្ត-វិហារ | ចំនួនបុព្វជិត |
|---|---|---|---|
| ព្រះពុទ្ធ | ៨០ | ១ | ២៩ |
| ឥស្លាម | ១៩ | ២ | |
| គ្រីស្ត | ១ | ១ | ៣០ |

### ង . ចំណូលស្រុក និងចំណាកស្រុក

ទំរង់នៃចំណូល និង ចំណាកស្រុកប្រែប្រួលទៅតាមរដូវកាល ដូចជា នៅរដូវប្រាំង ប្រជាពលរដ្ឋក្នុងឃុំនាំគ្នាចេញទៅរក ការងារបន្ថែមនៅតំបន់ផ្សេងៗដូចជា ជួញដូរ ធ្វើកម្មកររោងចក្រ ស៊ីឈ្នួលកំលាំងពលកម្ម។ល។ និងនៅរដូវវស្សា ពួកគេវិល ត្រលប់មកភូមិស្រុកវិញ ដើម្បីធ្វើស្រែ ចំការ មានចំនួន៧៤នាក់ ស្រ្តី៥២នាក់។

## ១.១.៣ ភាពគ្មានដីធ្លី

គ្រួសារគ្មានដីស្រែផ្ទាល់ខ្លួន មានចំនួន ១៤២ គ្រួសារ ដែលនៅរដូវប្រាំងប្រកបរបរនេសាទនៅតាមដៃព្រែក តំបន់ពៃលិចទឹក និងនៅរដូវវស្សា ស៊ីឈ្នួលដកស្ទូង ច្រូតកាត់ ។

គ្រួសារមានដីស្រែតិចជាង០១ហិកតាមានចំនួន២២៥គ្រួសារ ដែលត្រូវរករបរបន្ថែមទើបអាចហូបគ្រប់គ្រាន់ គឺនៅរដូវវស្សា ពួកគាត់ត្រូវ ស៊ីឈ្នួលដក ស្ទូង ច្រូតកាត់ និងនៅរដូវប្រាំងចេញទៅនេសាទនៅតាមដៃព្រែក តំបន់ព្រៃលិចទឹក ។

**តារាងចំនួនគ្រួសារដែលគ្មានដី និងមានដីមិនគ្រប់គ្រាន់**

| លរ | បរិយាយ | ចំនួនគ្រួសារ | ភាគរយ % | ផ្សេងៗ |
|---|---|---|---|---|
| ១ | គ្មានដីស្រែផ្ទាល់ខ្លួន | ១៤២ | ១៥.៩៧ | |
| ២ | មានដីស្រែតិចជាង ១ ហិកតា | ២២៥ | ២៥.៣០ | |

### ១.១.៤ ស្ថានភាពសេដ្ឋកិច្ច

ប្រជាពលរដ្ឋនៅក្នុងឃុំ អណ្តូងថ្ម ប្រមាណ ៨៦,៤៨ % មានមុខរបរធ្វើស្រែវស្សា ដោយពឹងផ្អែកលើប្រភពទឹកភ្លៀង និងការនេសាទ, អនុផលព្រៃឈើ និងដាំដំណាំ តែការដាំដំណាំនេះមិនសូវទទួលបានផលល្អប៉ុន្មានទេ។ ប្រជាពល រដ្ឋក្នុងឃុំបានពង្រីកមុខរបរបន្ថែម គឺទិញ និងលក់ភោគផលក្នុងមូលដ្ឋាន ( ស្រូវ ត្រី ក្តាម បង្គា ។ល។ ) លក់ចេញទៅ ក្រៅមូលដ្ឋាន និងបើកជាសិប្បកម្ម ធ្វើជាងឈើ ជាងជួសជុល ឡាន ម៉ូតូ ។ល។

#### ក. មុខរបរប្រជាពលរដ្ឋ

ប្រជាពលនៅឃុំអណ្តូងថ្មប្រកបមុខរបរដូចជា ធ្វើស្រែវស្សា ចំការ(ដំណាំរយៈពេលវែង) ដាំបន្លែ , នេសាទ , សិប្បកម្មខ្នាតតូច , លក់ដូរ , ជួសជុលម៉ូតូ និង សេវាកម្ម ដឹកជញ្ជូន ។

| ប្រភេទមុខរបរ | ចំនួនគ្រួសារ | | ផ្សេងៗ |
|---|---|---|---|
| | ចំនួនគ្រួសារ | ភាគរយ | |
| **គ្រួសារមានមុខរបរធ្វើកសិកម្មជាចំបង** | **៩៣២** | **៩០.៩៦** | |
| គ្រួសារមានមុខរបរធ្វើស្រែ | ៨៨៩ | ៨៦,៤៨ | ស្រែវស្សា |
| គ្រួសារមានមុខរបរដាំដំណាំរយៈពេលវែង | ១៩ | ១,៨៥ | ស្វាយ ដូង ខ្នុរ សាវមាវ ធូរេន.... |
| គ្រួសារមានមុខរបរដាំបន្លែ | ១៧ | ១,៦៥ | ត្រសក់ ត្រប់ សណ្តែកទ្រើង ........ |
| គ្រួសារមានមុខរបរនេសាទ | ៧ | ០,៦៨ | ត្រី ក្តាម បង្គា ............. |
| **គ្រួសារមានមុខរបរធ្វើកសិប្បកម្មជាចំបង** | **៣** | **០,២** | |
| គ្រួសារមានមុខរបរសិប្បកម្មដែកកញ្ចក់, អាលុយមីញ៉ូម | ២ | ០,១៩ | គ្រោងទ្វារ គ្រោងបង្អួច ...... |
| គ្រួសារមានមុខរបរសិប្បកម្ម ផ្សេងៗ | ១ | ០,១០ | |
| **គ្រួសារប្រកបមុខរបរសេវាកម្មជាចំបង** | **៩៣** | **៩.០៥** | |
| គ្រួសារប្រកបមុខរបរជំនួញ | ១០ | ០,៩៧ | លក់ គ្រឿងទេស ស្រូវ ក្រណាត់..... |
| គ្រួសារប្រកបមុខរបរជាង | ៣ | ០,២៩ | សំណង់ ( ឈើ បេតុង ) ........ |
| គ្រួសារប្រកបមុខរបរដឹកជញ្ជូន | ៤៤ | ៤.២៨ | តាក់ស៊ី ម៉ូតូ រឺម៉ក ............. |
| គ្រួសារប្រកបមុខរបរសេវាកម្មផ្សេងៗ | ៣៦ | ៣,៥០ | គុយទាវ កាហ្វេ បបរ ............ |
| ( ប្រភព:ឯកសារស្ថានភាពឃុំ ឆ្នាំ ២០០៩ ) | | | |

### ខ . ប្រភពមុខរបរ

ប្រជាពលរដ្ឋមានប្រភពចំណូលសំខាន់ៗពីរ គឺ : ចំណូលចំបង និងចំណូលបន្ទាប់បន្សំ

- ចំណូលចំបង : ស្រូវវស្សា អនុផលព្រៃឈើ ផលនេសាទសមុទ្រ ផលដំណាំរយៈពេលវែង លក់ដូរនៅទីផ្សារ រត់រឺម៉កម៉ូតូ ម៉ូតូឌុប រត់តាក់ស៊ីដឹកទំនិញ ។

- ចំណូលបន្ទាប់បន្សំ :ចិញ្ចឹមសត្វ ដំណាំរយៈពេលខ្លី នេសាទ និងប្រកបមុខរបរផ្សេងៗជាច្រើនទៀត ។

### គ .ចំណូល និង ចំណាយប្រចាំថ្ងៃ ប្រចាំឆ្នាំ

| ល.រ | បរិយាយ | ប្រជាពលរដ្ឋ |
|---|---|---|
| ១ | ចំណូលមធ្យម ១ថ្ងៃ/នាក់ / រៀល | ៤.០០០ ទៅ ៤.៥០០ |
| ២ | ចំណូលមធ្យម ១ឆ្នាំ / នាក់ / រៀល | ១.៤៦០.០០០ ទៅ ១.៦៤២.៥០០ |
| ៣ | ចំណាយ មធ្យម ១ថ្ងៃ/នាក់ / រៀល | ៣.០០០ ទៅ ៣៥០០ |
| ៤ | ចំណាយ មធ្យម ១ឆ្នាំ /នាក់ / រៀល | ១.០៩៥.០០០ ទៅ ១.២៧៧.៥០០ |

ប្រជាពលរដ្ឋចំណាយលើស្បៀងអាហារ សំលៀកបំពាក់ ឧបករណ៍ប្រើប្រាស់,ថ្នាំព្យាបាលសម្ភារះសិក្សានិង ពិធីបុណ្យផ្សេងៗ ។

### ឃ . ស្ថានភាពបំណុលអត្រាការប្រាក់

កង្វះឥណទានដែលមានការប្រាក់ទាប និងមានកំណត់ពេលវេលាសំរាប់សងវិញដែលជាហេតុបង្កអោយមាន ឧបស័គ្គធ្ងន់ធ្ងរដល់ការរំដោះខ្លួនចេញពីភាពក្រីក្រ ។ គ្រួសារជាច្រើនជួបប្រទះបញ្ហាលំបាកដូចជា មានជម្ងឺ ការប្រមូលផលស្រូវ ឬការដាំដំណាំបានតិចតួច តំរូវអោយមានប្រាក់កម្ចីសំរាប់រយះពេលកំណត់ណាមួយ ។

ប្រជាពលរដ្ឋប្រមាណ៧០% ជំពាក់ប្រាក់ធនាគារ ។ យោងតាមការពិភាក្សាជាមួយមន្ត្រីធនាគារមួយចំនួន ឃើញថា អត្រាការប្រាក់ក្នុង១ខែ មានដូចក្រោម :

- ធនាគារ អេស៊ីលីដា អត្រាការប្រាក់ ៣% ( កម្ចីតាមភូមិ )
- ធនាគារ អេ អឹម ខេ អត្រាការប្រាក់ ៣% ( កម្ចីតាមភូមិ )
- ធនាគារ អម្រិត អត្រាការប្រាក់ ៣.៥ ( កម្ចីតាមភូមិ )

### ង . ការប្រើប្រាស់មីក្រូឥណទានជាសាច់ប្រាក់ ឬក្រោមរូបភាពផ្សេងៗ

សាច់ប្រាក់ដែល ប្រជាពលរដ្ឋបានខ្ចីពីធនាគារ ត្រូវបានគេយកទៅប្រើប្រាស់ដូចជា : ពង្រីកមុខរបរ បង្កើតមុខរបរ (ទិញទូក ទិញឧបករណ៍នេសាទ ទិញសត្វចិញ្ចឹម) ជួសជុលឧបករណ៍នេសាទ ទិញជីបាចស្រូវ ព្យាបាលជំងឺ ។

### ច . ជំនួយពីប្រភពផ្សេងៗ :

- ផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ និងកម្មវិធីវិនិយោគឃុំ ។

## ១.១.៥.ស្ថានភាពអប់រំ និងសិក្សាធិការ

ឃុំអណ្តូងថ្មមានសាលារៀនមួយ ឈ្មោះ **សាលាបឋមសិក្សានិងអនុវិទ្យាល័យ ហ៊ុន សែន អណ្តូងថ្ម** មានអាគារមធ្យមសិក្សា១ខ្នងស្មើនឹង៥បន្ទប់ និងអាគាបឋមសិក្សា២ខ្នងស្មើនឹង១២បន្ទប់ ដែលស្ថិតនៅក្នុងបរិវេណវត្តមុន្នី សាលព្រឹក្ស ។

**តារាង ស្ថិតិសាលា និងចំនួនសិស្ស ប្រចាំឆ្នាំ២០០៨** ( ប្រភព: របាយការណ៍ ស្តីពីស្ថានភាពឃុំអណ្តូងថ្ម ឆ្នាំ ២០០៨ )

| ប្រភេទសាលា | ចំនួនសាលានៅឆ្នាំ ២០០៨ | | | ចំនួនកុមារ/សិស្សនៅឆ្នាំ ២០០៨ | | | អត្រាមិនចូលរៀន |
|---|---|---|---|---|---|---|---|
| | សាលា | បន្ទប់ | ថ្នាក់ | កុមារ | សិស្ស | សិស្សស្រី | |
| ថ្នាក់មត្តេយ្យសិក្សា | ០១ | ០២ | ០២ | ២៥៧ | ៦៤ | - | ៧៥% |
| ថ្នាក់បឋមសិក្សា | ០១ | ១០ | ១៩ | ៨១០ | ៦៥១ | ៣២៥ | ២០% |
| ថ្នាក់អនុវិទ្យាល័យ | ០១ | ០៤ | ០៦ | ៤៧៣ | ៤៤៣ | ២២៣ | ៦% |
| ថ្នាក់វិទ្យាល័យ | - | - | - | ៤២១ | ៣៥៦ | - | ១៥% |

លោកគ្រូ និង អ្នកគ្រូ ប្រចាំថ្នាក់មានចំនួន ៣៨នាក់ ក្នុងនោះមាន:

- លោកគ្រូ អ្នកគ្រូមធ្យមចំនួន ១៤ នាក់ ស្រី ០២ នាក់
- លោកគ្រូ អ្នកគ្រូបឋមចំនួន ២៤ នាក់ ស្រី ០៣ នាក់ ។

**ស្ថានភាពកុមារមិនបានចូលរៀនក៏រឹតបឋមសិក្សា**

ក្នុងឃុំអណ្តូងថ្មទាំងមូលអត្រាក្មេងគ្រប់អាយុមិនបានចូលរៀនមានអត្រាខ្ពស់ជាងគេនៅភូមិអណ្តូង, ភូមិបន្ទាយប្រិយ៍បន្ទាប់មកគឺភូមិភូមិត្រពាំងស្នុយ២ ។ចំណែកភូមិអូរត្រាវ និងភូមិត្រពាំងស្នុយ១ មានអត្រាប្រហាក់ប្រហែលគ្នា ។

| បរិយាយ | ចំនួន | | អត្រា % |
|---|---|---|---|
| | សរុប | ស្រី្ត | |
| កុមារអាយុពី៦ឆ្នាំ មិនបានរៀន | ១១៥ | - | ៤៤.០៦ |
| កុមារអាយុពី៦-១១ឆ្នាំ មិនបាន ចូលរៀន | ១៥៩ | ៦៨ | ១៩.៦៣ |




ក្រាភិកទី១: អត្រាកុមារគ្រប់អាយុតែមិនបានចូលរៀន

**<u>អត្រាអក្ខរកម្ម និង ករិតវប្បធមិ</u>**

ចំពោះប្រជាជនដែលមានអាយុពី១៥-៦០អត់ចេះអក្សរមានអត្រាប្រមាណ៥,៧៦%។ ដូច្នេះអត្រាអ្នកចេះអក្សរមានករិតប្រមាណ៩៤,២៤%។

| បរិយាយ | ចំនួន | | អត្រា % |
|---|---|---|---|
| | សរុប | ស្ត្រី | |
| អ្នកមិនចេះអក្សរអាយុពី១៥-៦០ឆ្នាំ | ១៦៨ | ៨៨ | ៥,៧៦ |

**<u>ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់</u>**

ឃុំអណ្តូងថ្មមានជនជាតិខ្មែរអ៊ីស្លាម(កាន់សាសនាមហាម៉ាត់)ប្រមាណជា១៩%ដូច្នេះការសិក្សាបន្តទៅ ថ្នាក់ខ្ពស់វាជាឧបស័គ្គមួយសំរាប់កុមារ ដោយចាស់ទុំតំរូវអោយកុមារទាំងនោះត្រឡប់មកសិក្សាគម្ពីធមិសាសនាទៅ វិញ ។ កុមារដែលមានលទ្ធភាពបន្តការសិក្សាមានចំនួនប្រមាណ៥៤នាក់តែប៉ុណ្ណោះនៅឆ្នាំ២០០៨ក្នុងនោះមាន ស្រី២៩នាក់។

| បរិយាយ | ចំនួន | | អត្រា % |
|---|---|---|---|
| | សរុប | ស្ត្រី | |
| សិស្សរៀននៅវិទ្យាល័យ | ៥៤ | ២៨ | ១២,៨២ |
| សិស្សរៀនគម្ពីសាសនា | ៣០២ | - | ៧១,៧៣ |

## ១.១.៦ <u>ស្ថានភាពសុខាភិបាល</u>

### ១.១.៦.១ <u>ផ្នែកសុខាភិបាល</u>

ឃុំអណ្តូងថ្មមណ្ឌលសុខភាព១ខ្នង ដែលមានទីតាំងស្ថិតនៅទល់មុខសាលាឃុំអណ្តូងថ្មមាន៤បន្ទប់ គ្រែ៤។ ក្នុង១ថ្ងៃ មានអ្នកជំងឺមកពិគ្រោះ និងព្យាបាលជំងឺពី ៣០នាក់ ទៅ៦០នាក់ ។

**គ្រូពេទ្យ ឆ្មប និង គ្រូបុរាណខ្មែរ**

មណ្ឌលសុខភាពឃុំមានបុគ្គលិកពេទ្យចំនួន៩នាក់(ពេទ្យឆ្មប២នាក់)និងមានឆ្មបបុរាណចំនួន៥នាក់ នៅតាមភូមិ។ តាមព័ត៌មានពីមណ្ឌលសុខភាពបានឱ្យដឹងថានៅឃុំអណ្តូងថ្ម មាតាសំរាល កូនតាមឆ្មបបុរាណ មានតែ ៣,៤១% ដែលឆ្លុះបញ្ចាំងអោយឃើញថាប្រជាពលរដ្ឋមានការយល់ដឹងពីសុខភាពសុវត្ថិភាពរបស់ខ្លួនកាន់តែប្រសើរឡើង។

**ប្រភេទជំងឺ :** ជំងឺដែលកើតមានដល់ប្រជាពលរដ្ឋ នៅក្នុងឃុំអណ្តូងថ្ម មាន ជំងឺអេដ៍ របេង គ្រុនឈាម ។ ជាក់ស្តែងអ្នកផ្ទុកមេរោគ អេដ៍មាន ៤គ្រួសារ ត្រូវជា 0,04% ។

**ការចាក់ថ្នាំ និង អាហារូបត្ថម្ភ**

កុមារនៅសង្កាត់អណ្តូងថ្ម បានទទួលការចាក់ថ្នាំបង្ការ ជម្ងឺ ១០០%(ឯកសារ មណ្ឌលសុខភាព ២០០៩) ។

**មធ្យោបាយជូនអ្នកជម្ងឺទៅកាន់មណ្ឌលសុខភាព ឃុំអណ្តូងថ្ម និងមន្ទីរពេទ្យបង្អែក**

ប្រជាពលរដ្ឋក្នុងឃុំ ទៅព្យាបាលជម្ងឺនៅមណ្ឌលសុខភាព ដែលមានចម្ងាយប្រមាណ ១,៥គ.ម ដោយប្រើ

មធ្យោបាយដូចជា ថ្មើរជើង ម៉ូតូជាដើម ។ ប្រជាពលរដ្ឋមានលទ្ធភាពក្នុងការព្យាបាលជំងឺ គេទៅគ្លីនិកឯកជនក្នុងឃុំវាលរេញឬមកមន្ទីរពេទ្យបង្អែកក្រុងព្រះសីហនុ ។ ជាមធ្យមការចំណាយធ្វើដំណើរពីផ្ទះមកមណ្ឌលសុខភាពមានតម្លៃ៥០០រៀល ពីមណ្ឌលសុខភាពទៅគ្លីនិកឯកជនឃុំវាលរេញមានតម្លៃ១.០០០រៀល ពីឃុំទៅមន្ទីរពេទ្យបង្អែកខេត្តព្រះសីហនុមានតម្លៃពី ៧០.០០០រៀល ទៅ៨០.០០០រៀល ។




### ១.១.៦.២ ការផ្គត់ផ្គង់ទឹកស្អាត

ការផ្គត់ផ្គង់ទឹកស្អាតនៅឃុំអណ្តូងថ្មពុំទាន់គ្រប់គ្រាន់តាមសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅឡើយ ។ ដោយឡែក ចំពោះអណ្តូងលូ អណ្តូងដៃ និងទឹកស្រះមួយចំនួន ត្រូវរីងស្ងួតនៅរដូវប្រាំង ។

តារាងស្ថិតិប្រភពទឹកប្រើប្រាស់នៅក្នុងឃុំ

| ល.រ | ប្រភពទឹកស្អាត | ចំនួនប្រភពទឹក | | | សំគាល់ |
|---|---|---|---|---|---|
| | | សរុប | ប្រើបាន | ខូចខាត/គ្មានទឹក | |
| ១ | អណ្តូងស្នប់ ឬ អណ្តូងចំរុះ | ២៩ | ២៨ | ១ | ប្រើបានពេញ១ឆ្នាំ និង ជួសជុល |
| ២ | អណ្តូងលូ | ១១១ | ៩២ | ១៩ | ប្រើបានពេញ១ឆ្នាំ និងគ្មានទឹកនៅរដូវប្រាំង |
| ៣ | អណ្តូងដៃមិនដាក់លូ | ១០៨ | ៩៤ | ១៤ | ប្រើបានពេញ១ឆ្នាំ និងគ្មានទឹកនៅរដូវប្រាំង |
| ៤ | ស្រះទឹក | ១៣ | ១០ | ៣ | ប្រើបានពេញ១ឆ្នាំ និងគ្មានទឹកនៅរដូវប្រាំង |
| ៥ | អាងស្តុកទឹក | ១ | ១ | - | ប្រើបានពេញ១ឆ្នាំ |

## ១.២. ស្ថានភាពភូមិសាស្ត្រ

### ១.២.១ ទីតាំងភូមិសាស្ត្រ

ឃុំអណ្តូងថ្ម ជាឃុំដែលមានផ្លូវជាតិលេខ៤ឆ្លងកាត់ ភាគខាងកើតនៃផ្លូវជាតិលេខ៤ ជាដី លំនៅដ្ឋាន ស្រែ និង ព្រៃលិចទឹក (ដើមកោងកាង) ភាគខាងលិចជាដីលំនៅដ្ឋាន ចំការដំណាំ និងព្រៃឈើ ។

ឃុំអណ្តូងថ្មមានសណ្ឋានដី ជាខ្ពង់រាប វាលទំនាប និងតំបន់សមុទ្រ ស្ថិតក្នុងរយៈកំពស់ :

- ពី ០ម-២៥ម វាលទំនាប (វាលស្រែ ព្រៃលិចទឹក)
- ពី ១២ម-៤០២ម ខ្ពង់រាប (ភ្នំ) ។

និងស្ថិតនៅចន្លោះ

- ពី ៣៥៥000 mE ទៅ ៣៧៦000 mE ( រយៈទទឹង ខាងកើត )
- ពី ១១៧៦000 mN ទៅ ១១៨៣000 mN ( រយៈបណ្តោយ ខាងជើង )



ប្រភពទឹកក្នុងឃុំអណ្តូងថ្មមាន: អាងស្តុកទឹកចុងអូរ, ដៃព្រែកតូចៗតាមភូមិ ទឹកភ្លៀង និងទឹកអណ្តូង។

ប្រភេទដីនៅក្នុងឃុំចែកចេញជា: ដីលំនៅដ្ឋាន ដីស្រែ ដីព្រៃលិចទឹក ដីចំការ ដីព្រៃភ្នំ។

-ដីលំនៅដ្ឋាន : លំនៅដ្ឋានរបស់ប្រជាពលរដ្ឋភាគច្រើនស្ថិតនៅសងខាងផ្លូវជាតិលេខ៤ និងមានប្រភេទជាដីល្បាយ ខ្សាច់លាយដីក្រហម។

-ដីស្រែ : ឃុំអណ្តូងថ្មមានផ្ទៃដីស្រែចំនួន១៧១១.២៧៥៩ហ.ត លាតសន្ធឹងពីភូមិទៅទល់ នឹងទំនប់ការពារទឹកប្រៃប៉ុលខ្មែរដែលជាដីមមោគខ្មៅ ល្បាប់សមុទ្រលាយល្បាយខ្សាច់ ។ ក្នុងមួយឆ្នាំប្រជាពលរដ្ឋធ្វើស្រែតែម្តងក្នុងរដូវវស្សានិងត្រូវពឹងផ្អែកទៅលើទឹកភ្លៀង។

-ព្រៃលិចទឹក :ស្ថិតក្នុងការការពារនិងអភិរក្សធនធានជលផលមាន៣៨៤,៤0 ហ.តដែលជាដី ល្បាប់សមុទ្រ

-ដីចំការ : ឃុំអណ្តូងថ្ម មានផ្ទៃដីចំការឈើហូបផ្លែ និងផ្ទៃដីចំការដំណាំសរុបចំនួន៥២៣.៦៥១៥ហ.ត ដែលជាដី កណ្តេងល្បាយខ្សាច់ ល្បាយគ្រួសក្រហម។ ដីចំការក្នុងឃុំភាគច្រើនដាំដំណាំជាលក្ខណះគ្រួសារ។

-ដីព្រៃភ្នំ : ឃុំអណ្តូងថ្មមានផ្ទៃដីព្រៃភ្នំសរុបចំនួនប្រមាណ២៣៥៥.១៥៣៣ហ.ត មានភ្នំនិងដីលាតសន្ធឹងរហូតទៅទល់នឹងព្រំប្រទល់ឃុំទំនប់រលកស្រុកស្ទឹងហាវ។ ដីភ្នំនេះមានប្រភេទជាដីគ្រួសក្រហម ល្បាយខ្សាច់ ដីកណ្តេង ដីខ្សាច់ លឿង និងថ្មាំងថ្មតូច ធំផុសចេញពីដី។

### ១.២.២ អាកាសធាតុ

របបទឹកភ្លៀង មានទំនាក់ទំនងទៅនឹងសណ្ឋានដីដូចជាមាត់សមុទ្រខ្ពង់រាបមានភ្លៀងធ្លាក់ច្រើនជាងទំនាបកណ្តាលដោយសារមានជួរភ្នំក្រវាញដែលជារបាំងមួយយ៉ាងធំធ្វើអោយតំបន់ទំនាបកណ្តាលទទួលនូវបរិមាណតិច។

យោងតាម ទិន្នន័យមន្ទីរធនធានទឹក និងឧតុនិយម ឆ្នាំ ២00៨ បង្ហាញថា :

- កំពស់ទឹកភ្លៀងអតិបរិមា ៩៥៧.៧ ម.ម ក្នុងខែ សីហា
- កំពស់ទឹកភ្លៀងអប្បរមា ១00 ម.ម ក្នុងខែ ធ្នូ




ក្រាភិកទី២: បរិមាណទឹកភ្លៀង

ឃុំអណ្តូងថ្មក៏ដូចជាខេត្តព្រះសីហនុដែរបានទទួលឥទ្ធិពលខ្យល់មូសុងត្រូពិចដូចគ្នា ហើយត្រូវចែកចេញជាពីររដូវ គឺ : រដូវប្រាំង និងរដូវវស្សា។

- <u>រដូវប្រាំង</u>:មានរយ:ពេល៦ខែចាប់ពីខែ (វិច្ឆិកា ដល់ មេសា) ។ នៅខែមីនា និងខែមេសា កំរិតសីតុណ្ហភាពអតិបរិមាពី៣០$^{0}$C ទៅ៣៤$^{0}$C នៅខែធ្នូ និងខែមករា កំរិតសីតុណ្ហភាពអប្បបរិមាពី១៩$^{0}$C,ទៅ ២១$^{0}$C ។

- <u>រដូវវស្សា</u> : មានរយ:ពេល៦ខែចាប់ពីខែ ( ឧសភា ដល់ខែ តុលា) ។
បរិមាណទឹកភ្លៀងមធ្យមប្រចាំឆ្នាំ ២០០៨ គឺ ៣៣៧៤.០៥មម ។

- <u>ល្បឿនខ្យល់</u> : នៅខែកញ្ញា ល្បឿនខ្យល់អតិបរិមា១៨ m / s ។

**ទូរលេខអាកាសធាតុដែលពិនិត្យឃើញ នៅស្ថានីយ៍ឧតុនិយមខេត្តព្រះសីហនុ ឆ្នាំ២០០៩**

| **ខែ** | **កំពស់ ទឹកភ្លៀង** | **សីតុណ្ហភាព គិតជា អង្សាសេ** | | | | **សំណើម** | **ទិស,ល្បឿន ខ្យល់** |
|---|---|---|---|---|---|---|---|
| | | **អតិបរិមា** | **អប្បរិមា** | **ស្ងួត** | **សើម** | មធ្យម | m / S |
| | ម.ម | មធ្យម | មធ្យម | មធ្យម | មធ្យម | ភាគរយ | |
| មករា | 2.4 | 30.1 | 22.8 | 27.5 | 22.3 | 90.5 | N-10 |
| កុម្ភះ | 6.8 | 31.1 | 22.7 | 27.3 | 25.2 | 84.6 | NE-05 |
| មីនា | 113.3 | 31.8 | 24.9 | 27.7 | 25.5 | 90.7 | SE-06 |
| មេសា | 127.4 | 32.3 | 25.6 | 28.5 | 26.0 | 87.0 | NW-07 |
| ឧសភា | 353.2 | 31.1 | 251 | 27.6 | 25.3 | 83.7 | NE-07 |
| មិថុនា | 141.5 | 31.3 | 25.3 | 27.8 | 25.6 | 83.2 | NW-13 |
| កក្កដា | 379.1 | 30.5 | 24.5 | 26.9 | 25.1 | 86.0 | NW-17 |
| សីហា | 220.8 | 31.3 | 25.2 | 27.7 | 25.5 | 83.1 | NW-09 |
| កញ្ញា | 715.1 | 29.5 | 24.0 | 26.1 | 24.6 | 89.1 | NW-18 |
| តុលា | 215.7 | 30.4 | 24.7 | 27.0 | 25.1 | 86.1 | NW-14 |
| វិច្ឆិកា | 14.4 | 31.8 | 25.4 | 27.8 | 25.3 | 80.2 | NE-10 |
| ធ្នូ | 52.7 | 31.1 | 23.0 | 26.9 | 24.1 | 79.9 | NE-09 |
| សរុប | 2342.4 | 372.3 | 293.2 | 328.8 | 299.6 | 1024.1 | |
| មធ្យម | | 31.2 | 24.4 | 27.4 | 25.0 | 85.3 | |

**បញ្ជាក់ :** ទិន្នន័យទូរលេខអាកាសធាតុពីស្ថានីយ៍ឧតុនិយមខេត្តព្រះសីហនុឆ្នាំ២០០៩

## តារាងទឹកភ្លៀងគិតពីឆ្នាំ ( ១៩៩៧-២០០៨ )

| ឆ្នាំ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1997 | 0.0 | 3.4 | 136.0 | 88.8 | 144.1 | 59.5 | 597.4 | 765.3 | 295.0 | 326.1 | 167.3 | 100.4 | 2683.3 |
| 1998 | 35.6 | 20.0 | 18.4 | 34.6 | 321.9 | 726.6 | 488.9 | 553.6 | 629.5 | 283.5 | 132.8 | 23.0 | 3268.4 |
| 1999 | 68.1 | 121.2 | 145.9 | 275.2 | 383.5 | 469.1 | 766.9 | 379.2 | 518.7 | 426.6 | 225.3 | 50.7 | 3830.4 |
| 200 | 70.8 | 82.3 | 66.6 | 289.6 | 298.5 | 538.3 | 434.0 | 957.7 | 111.4 | 506.2 | 57.7 | 25.5 | 3438.6 |
| 2001 | 115.6 | 62.2 | 165.9 | 156.1 | 430.7 | 589.1 | 294.1 | 847.0 | 308.1 | 370.2 | 32.5 | 26.0 | 3397.5 |
| 2002 | 7.4 | 6.8 | 84.9 | 183.2 | 403.9 | 431.0 | 256.2 | 930.9 | 518.4 | 70.5 | 190.3 | 89.6 | 3173.1 |
| 2003 | 0.0 | 4.4 | 244.7 | 71.1 | 327.9 | 432.4 | 472.9 | 477.1 | 390.2 | 383.5 | 23.6 | 3.6 | 2831.4 |
| 2004 | 39.5 | 25.4 | 53.0 | 192.4 | 424.5 | 546.5 | 849.0 | 733.2 | 282.5 | 143.1 | 71.5 | 0.0 | 3360.6 |
| 2005 | 51.1 | 0.4 | 48.4 | 170.6 | 322.5 | 454.3 | 705.1 | 366.3 | 383.2 | 258.7 | 68.9 | 67.6 | 2897.2 |
| 2006 | 121.6 | 127.6 | 79.9 | 197.0 | 447.0 | 562.4 | 927.3 | 611.4 | 519.3 | 349.8 | 92.0 | 29.5 | 4064.8 |
| 2007 | 2.5 | 3.9 | 134.7 | 227.1 | 270.4 | 289.1 | 695.2 | 449.3 | 820.1 | 316.6 | 125.6 | 30.2 | 3364.7 |
| 2008 | 0.0 | 33.2 | 145.2 | 189.4 | 396.2 | 482.2 | 335.3 | 435.4 | 484.6 | 370.7 | 87.8 | 0.1 | 2960.1 |
| Max | 121.6 | 127.6 | 244.7 | 289.6 | 447.0 | 726.6 | 927.3 | 957.7 | 820.1 | 506.2 | 225.3 | 100.4 | 4064.8 |
| Aver | 46.6 | 41.6 | 107.1 | 171.4 | 343.2 | 463.5 | 589.7 | 642.8 | 434.2 | 312.3 | 108.0 | 40.6 | 3300.9 |
| Min | 0.0 | 0.4 | 18.4 | 34.6 | 144.1 | 59.5 | 256.2 | 366.3 | 111.4 | 70.5 | 23.6 | 0.0 | 2683.3 |

( ប្រភព: មន្ទីរធនធានទឹក និង ឧតុនិយមខេត្តព្រះសីហនុ ឆ្នាំ ២០០៨ )

## ១.២.៣ ហេដ្ឋារចនាសម្ព័ន្ធ

ប្រព័ន្ធគមនាគមន៍ក្នុងឃុំអណ្តូងអាចអោយប្រជាពលរដ្ឋធ្វើចរាចរណ៍ទំនាក់ទំនងក្នុងភូមិបានប៉ុន្តែមិនគ្រប់គ្រាន់ទេ។ ឃុំអណ្តូងថ្មមានប្រព័ន្ធគមនាគមន៍ប្រភេទ: ផ្លូវគោក និងផ្លូវទឹក។

ក . **ផ្លូវគោក:** មាន៣៩ខ្សែ ដែលចែកចេញជាផ្លូវកៅស៊ូ ផ្លូវក្រាលគ្រួសក្រហម និងផ្លូវដីស (ថ្មើរជើង ផ្លូវរទេះ ..)

| កូដ | ប្រភេទផ្លូវ | ស្ថានភាព និងប្រវែងផ្លូវ (ម) | | សំគាល់ |
|---|---|---|---|---|
| | | ប្រវែងសរុប | ប្រវែងខូចខាត | |
| ១ | ផ្លូវក្រាលកៅស៊ូ | ៣៨០០ | | ផ្លូវជាតិលេខ៤ |
| ៥ | ផ្លូវក្រាលគ្រួសក្រហម/ខ្សាច់ភ្នំ | ១១៩៥០ | | ទូទាំងឃុំធ្វើឡើងនៅឆ្នាំ ២០០៦ - ២០០៨ |
| ៧ | ផ្លូវដីស (ថ្មើរជើង ......... ) | ១៦១០៣ | ១៦១០៣ | ទូទាំងឃុំអណ្តូងថ្ម |

១. ផ្លូវក្រាលកៅស៊ូមានព្រំប្រទល់ ពីឃុំទួលទទឹង ដល់ព្រំប្រទល់ឃុំសំរុង។

២. ផ្លូវក្រាលគ្រួសក្រហម ១៧ខ្សែ ក្នុងនោះ ខាងលិចថ្នល់មាន ៥ខ្សែ និងខាង ខាងកើតថ្នល់មាន១២ខ្សែ។

៣. ផ្លូវដីស (ថ្មើរជើង ....) មាន១៧ខ្សែ: ខាងលិចថ្នល់មាន ១១ខ្សែ និងខាង ខាងកើតថ្នល់មាន៦ខ្សែ ។



ផ្លូវដីស



ផ្លូវក្រាលគ្រួសក្រហម

ខ .**ផ្លូវទឹក** ក្នុងឃុំអណ្តូងថ្មមានចំនួន៣ខ្សែ : ប្រឡាយជ្រឹងជ្រង ប្រឡាយបន្ទាយប្រើយនិងប្រឡាយអូរត្រាវ ដែលអាចធ្វើដំណើរ បានដល់ទំនប់បារាំងទាំងក្នុងរដូវវស្សា និងរដូវប្រាំង ។



គ. **មធ្យោបាយដឹកជញ្ជូន** ៖ ការដឹកជញ្ជូននៅក្នុងឃុំ ធ្វើឡើងក្រោមរូបភាពដូចជារថយន្ត ម៉ូតូ កង់ រទេះគោ-ក្របី ទូកយន្ត ទូកចែវ-អុំ។




## ១.៣ ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

### ១.៣.១ ស្ថានភាពនៃការប្រើប្រាស់ដី

ផ្អែកលើ ការប្រើប្រាស់ដី ឃុំអណ្តូងថ្ម ចែកចេញជា ២ប្រភេទ ៖

- ការប្រើប្រាស់ដីសាមញ្ញបច្ចុប្បន្ន
- ការប្រើប្រាស់ដីលំអិត

## តារាងចំណាត់ថ្នាក់ប្រើប្រាស់ដីសាមញ្ញបច្ចុប្បន្ន

| កូដ | ចំណាត់ថ្នាក់ប្រើប្រាស់ដី (តាមបច្ចេកទេស) | ចំណាត់ថ្នាក់ប្រើប្រាស់ដី (តាមមូលដ្ឋាន) | ក្រឡាផ្ទៃ | |
|---|---|---|---|---|
| | | | គម.ក្រឡា | ហិកតា |
| | លំនៅដ្ឋាន | ដីភូមិ | 1.4898 | 148.98 |
| | កសិកម្ម | ដីស្រែ ដីចំការ | 22.3492 | 2234.92 |
| | ព្រៃឈើ | ដីភ្នំ | 23.5515 | 2355.15 |
| | ព្រៃកោងកាង | ព្រៃលិចទឹក | 1.0727 | 107.27 |
| | វាលស្មៅ វាលស្មៅ | វាលស្មៅ វាលស្មៅ | 0.2874 | 28.74 |
| | ប្រភពទឹក | បឹង , ព្រែក , អាង | 0.1843 | 18.43 |
| | ដីដែលគ្មានរុក្ខជាតិ ដុះគ្របដណ្តប់ | ដីវាល | 0.0134 | 1.34 |
| សរុប | | | 48.9485 | 4894.85 |



តារាង ចំណាត់ថ្នាក់ប្រើប្រាស់ដីលំអិតបច្ចុប្បន្ន

| កូដ | ចំណាត់ថ្នាក់ប្រើប្រាស់ដី (តាមបច្ចេកទេស) | ចំណាត់ថ្នាក់ប្រើប្រាស់ដី (តាមមូលដ្ឋាន) | ក្រឡាផ្ទៃ | |
|---|---|---|---|---|
| | | | គម.ក្រឡា | ហិកតា |
| 1200 | ដីលំនៅដ្ឋានភូមិ | ដីភូមិ | 1.466925 | 146.6925 |
| 1320 | ដីកប់ខ្មោច | ដីស្មសាន | 0.022907 | 2.2907 |
| 2110 | ស្រូវវស្សា | ដីស្រែ | 16.170042 | 1617.0042 |
| 2111 | ដីស្រែជាមួយភូមិ | ដីថ្នាល | 0.942717 | 94.2717 |
| 2200 | ចំការដំណាំ | ដីចំការ | 5.236515 | 523.6515 |
| 3400 | ព្រៃដុះឡើងវិញ | ដីភ្នំ | 23.551533 | 2355.1533 |
| 3610 | ព្រៃកោងកាងស្តើង | ព្រៃលិចទឹក | 1.072703 | 107.2703 |
| 4100 | វាលស្មៅ | វាលស្មៅ | 0.037896 | 3.1816 |
| 4110 | ចំការបោះបង់ដុះស្មៅ | ដីវាល | 0.255586 | 25.5586 |
| 5210 | ទន្លេ ស្ទឹង អូរ | បឹង , ព្រែក , អាង | 0.145517 | 14.5517 |
| 5220 | សមុទ្រ | សមុទ្រ | 0.038809 | 3.8809 |
| 6300 | ផ្ទាំងថ្មដុះពីដី | វាលថ្ម | 0.01344 | 1.344 |
| សរុប | | | 48.94821 | 4894.821 |




## ទិន្នន័យ ដែលផ្តល់ពីឃុំ

| កូដ | ចំណាត់ថ្នាក់ប្រើប្រាស់ដី (តាមបច្ចេកទេស) | ចំណាត់ថ្នាក់ប្រើប្រាស់ដី (តាមមូលដ្ឋាន) | ក្រឡាផ្ទៃ | |
|---|---|---|---|---|
| | | | គម.ក្រឡា | ហិកតា |
| 1200 | ដីលំនៅដ្ឋានភូមិ | ដីភូមិ | 1.10 | 110 |
| 2110 | ស្រូវវស្សា | ដីស្រែ | 13.17 | 1317 |
| 2200 | ចំការដំណាំ | ដីចំការ | 6.92 | 692 |
| 3400 | ព្រៃដុះឡើងវិញ | ដីភ្នំ | 29.3217 | 2932.17 |
| 3610 | ព្រៃកោងកាងស្តើង | ព្រៃលិចទឹក | 1.072 | 107.2 |
| សរុប | | | 51.5837 | 5158.37 |

<u>កំណត់សំគាល់</u>

- ដីលំនៅដ្ឋានភូមិ , ស្រូវវស្សា (ទិន្នន័យពីលក្ខណ:ប្រព័ន្ធ)
- ចំការដំណាំ ព្រៃដុះឡើងវិញ (ទិន្នន័យឃុំ)
- ព្រៃកោងកាងស្តើង (ទិន្នន័យខណ្ឌរដ្ឋបាលជលផលខេត្ត)

## ១.៣.២ ស្ថានភាពនៃការគ្រប់គ្រង និងការកាន់កាប់ដី

ស្ថានភាពនៃការគ្រប់គ្រង និងកាន់កាប់ដីនៅក្នុងឃុំអណ្ដូងថ្ម ក្រៅពី : ដីលំនៅដ្ឋាន ដីស្រែ ចំការដំណាំ ចំការឈើ ហូបផ្លែដែលជាដីកម្មសិទ្ធិរបស់ឯកជន ឯដីសាធារណៈរបស់រដ្ឋមានដូចជា :

សហគមន៍នេសាទ : គ្រប់គ្រងធនធានជលផល២២២៩ ហ.ត ។

| ល.រ | ចំណាត់ថ្នាក់នៃការគ្រប់គ្រង និងកាន់កាប់ដី | | ក្រឡាផ្ទៃ (ហិកតា) |
|---|---|---|---|
| | តាមច្បាប់អនុញ្ញាត្តិ និងតួនាទី | តាមចំណាត់ថ្នាក់ដីរដ្ឋ និងដីឯកជន | |
| ១ | ដីព្រៃសហគមន៍ នេសាទការពារព្រៃលិចទឹក | ដីសាធារណៈ/ឯកជនរបស់រដ្ឋ | |
| ១ | ព្រៃកោងកាង | ដីសារធារណៈរបស់រដ្ឋ | **១០៧,២៧** |
| ២ | ព្រៃកោងកាងទើបដាំថ្មី | ដីសារធារណៈរបស់រដ្ឋ | **៣** |
| ៣ | ព្រៃឈើ | ដីសារធារណៈរបស់រដ្ឋ | **២៣៥៥.១៥** |
| ប្រភព: ទិន្នន័យGIS ប្រមូលពីមន្ទីរជំនាញពាក់ព័ន្ធជុំវិញ ជលផល | | | |

### ស្ថានភាពនៃការគ្រប់គ្រង និងកាន់កាប់ដីនីមួយៗ

ដីព្រៃលិចទឹកភូមិបន្ទាយប្រិយ៍ត្រូវបានបង្កើតជាសហគមន៍ការពារព្រៃលិចទឹក ដោយមានចំណារទទួលស្គាល់ពីអភិបាលក្រុង នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០៥ ដោយបានចងក្រងលក្ខន្តិកៈ និងផែនការគ្រប់គ្រងសហគមន៍។ សហគមន៍ព្រៃលិចទឹកភូមិបន្ទាយប្រិយ៍ បង្កើតឡើងដោយការឯកភាពរវាងប្រជាពលរដ្ឋក្នុងភូមិនិងក្រោមការឧបត្ថម្ភគាំទ្រដោយកម្មវិធីសិលានិងការិយាល័យជលផលក្រុងព្រះសីហនុ។ ភារៈកិច្ចរបស់សហគមន៍គឺការការពារ និងអភិរក្សធនធានជលផលដែលមាននៅក្នុងតំបន់គ្រប់គ្រងដូចជាតំបន់ឆ្នេរ តំបន់ព្រៃលិចទឹកនិងតំបន់ដៃព្រែកប្រឡាយដែលមាននៅក្នុងឃុំ និងមានសមាជិកចំនួន ២១២នាក់ ស្រី៩៥នាក់។

## ១.៣.៣ ផលិតកម្មកសិកម្ម

### ក.ផលិតកម្មដំណាំស្បៀង

ប្រជាពលរដ្ឋនៅក្នុងឃុំអណ្ដូងថ្មប្រមាណ៨៦,៤៨% មានមុខរបរធ្វើស្រែវស្សា ដោយពឹងផ្អែកលើទឹកភ្លៀង និងទំនប់ទឹកប្រៃ ។នៅក្នុងការប្រើប្រាស់ទឹកបំរើអោយវិស័យកសិកម្មឃើញថាឃុំអណ្ដូងថ្មមានអាងស្តុកទឹកចុងអូរមួយកន្លែងដែលប្រើរួមគ្នាជាមួយជាឃុំសំរុង ជាប្រភពទឹកដ៏សំខាន់ តែមិនអាចផ្គត់ផ្គង់ទឹកដល់ការស្រោចស្រពសំរាប់ការបង្កបង្កើនផលបានឡើយពីព្រោះទ្វារទឹកខូចនិងPHរបស់ដីមានកំរិតខ្ពស់នៅរដូវប្រាំង(សារជាតិជូរ) ជាហេតុនាំអោយឃុំអណ្ដូងថ្ម ធ្វើស្រែបានតែមួយរដូវ។

ឃុំអណ្ដូងថ្មមានទំហំដី សំរាប់ដំណាំស្រូវ ចំនួន១៧១១,២៧៥៩ ហ.ត ដែលដីមានប្រភេទជាដីមោគ, ល្បាប់ខ្មៅនិងដីស្អិតក្នុងតំបន់ដែលមានផលិតភាពទាប។ កសិករក្នុងឃុំអណ្ដូងថ្ម និយមប្រើប្រភេទពូជស្រូវដូចជា : ផ្ការំដួល ផ្កាម្លិះ ហៃរិន សតាឡុង សធំ ចាំឡុង ផ្កាត្រគៀត។

## តារាងក្រឡាផ្ទៃតាមផលិតភាពដី  ការប្រើប្រាស់ និងផលិតផល

| ល.រ | ចំណាត់ថ្នាក់ដីមានជីជាតិ (តាមបច្ចេកទេស) | ចំណាត់ថ្នាក់ដីមានជីជាតិ (តាមមូលដ្ឋាន) | ក្រឡាផ្ទៃ ហិកតា | ផ្សេងៗ |
|---|---|---|---|---|
| **ដីមានផលិតភាពទាប** | | | | |
| ១ | ដីលំនៅដ្ឋានភូមិ | ល្បាយខ្សាច់   ដីកណ្តេង | 146.6925 | ស្វាយ , ដូង |
| ២ | ដីកប់ខ្មោច | ល្បាយខ្សាច់ | 2.2907 | **កប់ខ្មោច** |
| ៣ | ស្រូវវស្សា | ដីមមោគ   ល្បាប់ខ្មៅ | 1617.0042 | ផ្ការំដួល ផ្កាម្លិះ ហៃវិន សតាឡុង សធំ |
| ៤ | ដីស្រែជាមួយភូមិ | ល្បាយខ្សាច់  ដីកណ្តេង | 94.2717 | ទីសំណាប , ថ្នាលសំណាប |
| ៥ | ចំការដំណាំ | ល្បាយខ្សាច់  ដីកណ្តេង ដីក្រហម | 523.6515 | ស្វាយ , ដូង , ខ្នុរ  ឥឡឹក ពោត  ម្រេចសណ្តែកទ្រើង |
| ៦ | ព្រៃដុះឡើងវិញ | ដីកណ្តេង   ដីក្រហមលាយគ្រួសក្រហម | 2355.1533 | ព្រីង  ស្វាយចំរៀង កកោះ គគីរសាច  ផ្តៅ  វល្លិ៍គ្រប់ប្រភេទ |
| ៧ | ព្រៃកោងកាងស្តើង | ល្បាប់សមុទ្រ | 107.2703 | ដើមកោងកាង   ក្រញឹប ប្រសាក់ |
| ៨ | វាលស្មៅ | ដីកណ្តេងលាយល្បាយខ្សាច់ | 3.1816 | ស្មៅ   ស្បូវ |
| ៩ | ចំការបោះបង់ដុះស្មៅ | ដីកណ្តេងលាយល្បាយខ្សាច់ | 25.5586 | ស្មៅ   ស្បូវ |
| ១០ | ទន្លេ  ស្ទឹង  អូរ | ភក់លាយខ្សាច់ | 14.5517 | ត្រីផ្ទក់  អណ្តែង  ក្រាញ់ កន្ត្រប |
| ១១ | សមុទ្រ | ល្បាប់សមុទ្រលាយខ្សាច់សមុទ្រ | 3.8809 | បង្គា  ក្តាមសេះ  ក្តាមថ្មមឹក |
| ១២ | ផ្ទាំងថ្មដុះពីដី | ថ្ម | 1.344 | ថ្មភ្នំ |
| សរុប | | | 4894.821 | |




<u>ប្រភពទឹក និងការស្រោចស្រព</u> :

ប្រជាពលរដ្ឋភាគច្រើនពឹងផ្អែកទាំងស្រុងលើទឹកភ្លៀង ក្នុងការស្រោចស្រពស្រូវវស្សា ។ រីឯអាងស្តុកទឹក ចុងអូរ ប្រឡាយ ដៃព្រែក មិនអាចផ្តល់ជាប្រភពស្រោចស្រពនារដូវប្រាំងបានឡើយ ។

**តារាងប្រព័ន្ធស្រោចស្រព**

| កូដ | ប្រភេទប្រព័ន្ធស្រោចស្រព | ស្ថានភាព និងប្រវែងផ្លូវ (ម) | | សំគាល់ |
|---|---|---|---|---|
| | | ប្រវែងសរុប | មិនទាន់ស្តារ | |
| ១ | ប្រឡាយជីងជ្រង (ប្រឡាយមេ) | ៦៧០០០ម | ១៣០០០ម | -ប្រឡាយជីងជ្រងស្តារហើយប្រវែង១៥០០ម នៅក្នុងភូមិអណ្តូងថ្ម ឆ្នាំ............. |
| ២ | ប្រឡាយបន្ទាយប្រិយ៍ (ប្រឡាយមេ) | ៦៧០០០ម | ៦០០០០ម | - ស្តារ ប្រវែង៧០០ម |
| ៣ | ប្រឡាយអូរត្រាវ (ប្រឡាយមេ) | ១៨០០ម | ១៨០០ម | - ភូមិអូរត្រាវ បានស្តាររួចរាល់ហើយ |
| ៤ | ព្រែកស្នាច់ទេវ | ២៥០០ម | ០ | - ភូមិអណ្តូងថ្ម ទាមទារត្រូវស្តារឡើងវិញស្រុង |
| ៥ | ព្រែកផ្ទះតាយេប | ៤៥០០ម | ០ | - ភូមិអណ្តូងថ្ម ទាមទារត្រូវស្តារឡើងវិញស្រុង |

| | | | | |
|---|---|---|---|---|
| ៦ | ព្រែកឃុំ | ២០០០ម | ០ | - ភូមិអណ្តូងថ្ម ទាមទារត្រូវស្តារឡើងវិញស្រុង |
| ៧ | ព្រែកកួនកុក | ៣០០០ម | ០ | - ភូមិត្រពាំងស្អុយមួយ |
| ៨ | ព្រែកបន្ទាយប្រីយ | ៥០០០ម | ០ | - ភូមិត្រពាំងស្អុយមួយ |
| ៩ | ព្រែកតាសេក | ៣០០០ម | ០ | - ភូមិអូរត្រាវ ទាមទារត្រូវស្តារឡើងវិញស្រុង |
| ១០ | ព្រែកឃ្លងធំ | ៧០០០ម | ០ | - ភូមិអូរត្រាវ ទាមទារត្រូវស្តារឡើងវិញស្រុង |



រូបភាពប្រឡាយជ្រីងជ្រង



**ទិន្នផលស្រូវ :**

- អតិបរិមា ២,៥ តោន/ហ.ត ។
- អប្បបរិមា ១,៨ តោន/ហ.ត ( ទិន្នន័យឃុំឆ្នាំ២០០៨) ។
- ទិន្នផលមធ្យម ២,៣ តោន/ហ.ត ( ទិន្នន័យឃុំឆ្នាំ២០០៨) ។

**ឱកាស :**

- ផ្ទៃដីស្រូវវស្សា ៣៤,៩៦% នៃផ្ទៃដីរួមរបស់ឃុំ ( ផ្ទៃដីធំទូលាយ) ។
- គាំទ្រពីដៃគូអភិវឌ្ឍន៍ឃុំ លើប្រព័ន្ធធារាសាស្ត្រ ។
- ភ្លៀងធ្លាក់ទៀងទាត់នៅរដូវវស្សា អាចធ្វើស្រែវស្សាបានរៀងរាល់ឆ្នាំ ។
- តំរូវការទីផ្សារ ។

**ឧបសគ្គ :**

- សត្វល្អិតស៊ីបំផ្លាញស្រូវ និងជម្ងឺស្រូវ ។
- ខ្យល់ខ្លាំង ធ្វើអោយស្រូវស្អក ។
- ទឹកជន់លិចនៅរដូវវស្សា ។
- ខ្វះការជ្រើសរើសពូជ ។
- ប្រជាជនខ្វះការយកចិត្តទុកដាក់ចូលរួមក្នុងការផ្សព្វផ្សាយរបស់មន្ទីរកសិកម្ម ។

**ខ. ផលិតកម្មដំណាំរួមផ្សំ**

ឃុំអណ្តូងថ្ម មានផ្ទៃដី សំរាប់ផលិតកម្ម ដំណាំផ្សេងៗ សរុប ៩២៣,៦៩១៥៤ ហ.ត។

**ប្រភេទដី និង ដីជាតិ**

ដីសំរាប់ដាំដំណាំរួមផ្សំ ជាប្រភេទដី កណ្តេង ល្បាយខ្សាច់ ដីក្រហម និង ស្ថិតក្នុងតំបន់ដែលមានផលិតភាពទាប ។

**តារាងប្រភេទដំណាំកសិកម្ម សំខាន់ៗ និងទិន្នផលទទួលបាន**

| ល.រ | បរិយាយ | ឯកតា ( តោន/ហិកតា ) |
|---|---|---|
| ១ | ពោត | ១.៥ |
| ២ | សណ្តែកទ្រើង | ២.៥ |
| ៣ | ឪឡឹក | ២.0 |
| ៤ | ត្រសក | ២.៥ |
| ៥ | ដំឡូងមី | ២.0 |
| ៦ | ដំឡូងជ្វា | ២.0 |
| ៧ | ម្រេច | 0.៥ |

**ឱកាសៈ**

- មន្ទីរកសិកម្មចុះផ្សព្វផ្សាយបច្ចេកទេស កសិកម្ម ។
- តម្រូវការទីផ្សារ ។
- គាំទ្រពីដៃគូអភិវឌ្ឍន៍ឃុំ ។

**ឧបសគ្គៈ**

- សត្វល្អិតស៊ីបំផ្លាញដំណាំ និងជម្ងឺដំណាំ ។
- ចំណេះដឹងផ្នែកបច្ចេកទេសកសិកម្មនៅមានកំរិត ។
- តំលៃទីផ្សារគ្មានស្ថិរភាព ។
- គ្មានប្រភពទឹកនៅរដូវប្រាំង ។

**ផលិតកម្មដំណាំឧស្សាហកម្ម**

ឃុំអណ្តូងថ្ម មិនមានដំណាំឧស្សាហកម្មទេ ។

### ១.៣.៤ ធនធានធម្មជាតិ

#### ១.៣.៤.១ ធនធានព្រៃឈើ

ផ្ទៃដីព្រៃនៅក្នុងឃុំអណ្តូងថ្មមាន២៣៩៥,១៥៣៣ហ.ត ស្ថិតនៅផ្នែកខាងលិចនៃឃុំលាតសន្ធឹងរហូតទៅទល់នឹងឃុំទំនប់រលកស្រុកស្ទឹងហាវ និងឃុំទួលទទឹងឃុំសំរុងស្រុកព្រៃនប់ ។ ព្រៃឈើមានមុខនាទីផ្នែកអេកូឡូស៊ី និងផ្នែកសេដ្ឋកិច្ចយ៉ាងសំខាន់ដូចជាការពារការហូរច្រោះ ស្រូបនូវឧស្ម័នកាបូនិចនិងបញ្ចេញអុកស៊ីសែនបង្កើតជីជាតិដល់ដី និងជាជំរកសត្វព្រៃ ។ កាលពីដើមជាប្រភេទ ព្រៃស្រោងនិងពាក់កណ្តាលស្រោង បច្ចុប្បន្នក្លាយជាប្រភេទព្រៃដុះឡើងវិញ ព្រៃគម្ពោចលាតដើមឈើធំមួយៗ ។ ក្រៅពីឈើសំរាប់សំណង់បន្ទាប់បន្សំនិងឈើសំរាប់ថាមពល នៅមានអនុផលព្រៃឈើ ឈើឱសថ ។ល។

ប្រភេទរុក្ខជាតិរួមមាន : គគីរខ្សាច់, ផ្ចុង, ត្រសេក, នាងដែង, ព្រីង, បង្គងក្អែក (ឈើសំណង់) ។

អនុផលព្រៃឈើ : សំរ៉ង, ផ្តៅ, ផ្សិត, ឃ្មុំ ...............

ឈើឱសថ : វល្លិអន្ទង់ , វល្លិរមៀត , វល្លិឈាម ...........

សត្វព្រៃ : ត្រគួត , អណ្តើក សំពោច ស្កាំ កំប្រុក ប្រម៉ា ឈ្លូស ទន្សាយ ........ ។

**ឱកាស**

- ធ្វើសហគមន៍ព្រៃឈើ ។
- តំរូវទីផ្សារ ។
- កាត់បន្ថយភាពក្រីក្រ របស់ប្រជាពលរដ្ឋ ។
- លក់ឥណទានកាបោន ។

**ឧបសគ្គ**

- លួចកាប់ព្រៃឈើ, ដុតព្រៃដើម្បីចាប់សត្វ,បាត់បង់ជម្រកសត្វព្រៃ ។ល។

- ប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ី ។

### ១.៣.៤.២ ធនធានជលផល

ឃុំអណ្តូងថ្មមានសហគមន៍ព្រៃលិចទឹកស្ថិតនៅភាគខាងកើត មាន១០៧ ,២៧ ហិកតា ដែលជាជំរកមច្ឆាជាតិ និងផ្តល់ជាអាហារដល់ប្រជាពលរដ្ឋក្នុងឃុំ និងលក់ទៅក្រៅ ។ ឃុំអណ្តូងថ្មមានដែននេសាទពីរប្រភេទ :ដែននេសាទទឹកសាប និងដែននេសាទទឹកប្រៃ ។

ដែននេសាទទឹកសាបមាន : អូរ,ប្រឡាយ,ឃ្លោង,ព្រែក,អាងស្តុកទឹក ។

ធនធានជលផលទឹកសាប : ក្តាម,ត្រីរស់,ត្រីផ្ទក់,ត្រីក្រាញ់,ត្រីឆ្លាត,ត្រីអណ្តែង ,ត្រីចង្វាក្រោស.កំពិស..... ។

ដែននេសាទទឹកប្រៃមាន : ដៃព្រែក និង ឃ្លោងព្រៃកោងកាង, សមុទ្រ ។

ធនធានជលផលទឹកប្រៃ : ក្តាមសេះ, ក្តាមថ្ម, ក្តាមជ័រ, បង្គា, ត្រីក្បក, ត្រីអណ្តែងប៉ុយ, ត្រី ក្អុក.... ។

ការនេសាទទឹកសាបប្រើឧបករណ៍ដូចខាងក្រោម : សន្ទូចរនង, បង្កៃ,មង, លប, ទ្រូ, ឡឺ, អង្រុត, ឈ្នាង ។

ការនេសាទទឹកប្រៃប្រើឧបករណ៍ដូចខាងក្រោម : លបក្តាមថ្ម, លបក្តាមសេះ, មងត្រីក្បក, មងត្រីចំរុះ, ឈីបដៃ (បង្គានិងគី), ផ្ទុងផាង, សន្ទូចអណ្តែងប៉ុយ...។

**ឱកាស**

- មានសហគមន៍នេសាទគ្រប់គ្រងធនធានជលផល ។
- តំរូវទីផ្សារ ។
- កាត់បន្ថយភាពក្រីក្រ របស់ប្រជាពលរដ្ឋ ។

**ឧបស័គ្គ**

- ការឆក់ត្រី ,ប្រើឈីបយន់ និងការចាប់យកគ្រែងតូចៗ ( ប្រើឧបករណ៍ខុសច្បាប់ ) ។
- សង់លំនៅដ្ឋានលើព្រៃលិចទឹក ។
- ការធ្វើអ្វូទូក ក្នុងតំបន់ព្រៃលិចទឹក ។



ថ្នាលបណ្តុះកូនកោងកាងនៅសហគមន៍បន្ទាយប្រីយ

## ១.៤ ទីផ្សារ និងខ្សែចង្វាក់ផលិតផល

### ១.៤.១ ទីផ្សារនិងតម្លៃកសិផល ផលអនុផលព្រៃឈើនិងផលនេសាទ

ផលិតផលដែលសល់ពីតំរូវការក្នុងគ្រួសារ ប្រជាពលរដ្ឋនៅឃុំប្រមូលភោគផលទៅលក់នៅទីផ្សារវាលវេញ ព្រៃនប់ ផ្សារលើ និងនាំចេញទៅប្រទេសវៀតណាមតាមរយៈឈ្មួញកណ្តាល។ ផលិតផលទាំងនោះ គឺស្រូវ អង្ករ ផលនេសាទ និងដំណាំ រួមផ្សំ ដូចជា ផ្លែដូង ផ្លែឪឡឹក ផ្លែត្រសក់ គ្រាប់ម្រេចជាដើម ហើយនាំចូលមកវិញមានដូចជាគ្រឿងទេស សំភារៈប្រើប្រាស់ សំលៀកបំពាក់ និងគ្រឿងសំណង់ជាដើម។

**តារាងទី៣: តំលៃកសិផល អនុផលព្រៃឈើ និងផលនេសាទ**

| ល.រ | រាយមុខទំនិញ | ឯកត្តា | តំលៃឯកត្តា (រៀល) |
|---|---|---|---|
| ១ | ស្រូវ | គ.ក្រ | ៨០០ |
| ២ | អង្ករ | គ.ក្រ | ១.៤០០ |
| ៣ | ដំឡូងឈើ | គ.ក្រ | ៨០០ |
| ៤ | ដំឡូងជ្វា | គ.ក្រ | ១.០០០ |
| ៥ | ម្រេច លេខ១ | គ.ក្រ | ១៨.០០០ |
| ៦ | ដូង | ផ្លែ | ៥០០ |
| ៧ | ឪឡឹក | ផ្លែ | ២.០០០ |
| ៨ | ត្រសក់ | គ.ក្រ | ១.៥០០ |
| ៩ | ស្ករត្នោត | គ.ក្រ | ៣.០០០ |
| ១០ | ត្រីរស់ | គ.ក្រ | ១០.០០០ |
| ១១ | ត្រីអណ្តែង ត្រីឆ្តក់ | គ.ក្រ | ៨.០០០ |
| ១២ | ត្រីក្រាញ់ | គ.ក្រ | ៧.០០០ |
| ១៤ | ក្តាមថ្ម | គ.ក្រ | ៣០.០០០ |
| ១៥ | ក្តាមជ័រ | គ.ក្រ | ៣.០០០ |
| ១៦ | បង្គារ | គ.ក្រ | ១៥.០០០ |
| ១៧ | សំរ៉ង | គ.ក្រ | ២៥.០០០ |
| ១៨ | ជ័រចុង | គ.ក្រ | ៧.០០០ |
| ១៩ | ផ្តៅ | ដើម | ២.០០០ |

( **ប្រភព**: ស្រាវជ្រាវទីផ្សារវាលវេញ ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ )

### ១.៤.២.ខ្សែសង្វាក់ និងចរាចរផលិតផល

ក.កសិផល




**ដ្យាក្រាមទី១: លំហូរកសិផលឃុំអណ្តូងថ្ម**

ខ.អនុផលព្រៃឈើ




**ដ្យាក្រាមទី២: លំហូរអនុផលឃុំអណ្តូងថ្ម**

គ.<u>ផលិតផលនេសាទ</u>




**ដ្យាក្រាមទី៣ៈ លំហូរផលនេសាទឃុំអណ្តូងថ្ម**

## ១.៤.៣ ឱកាសនិងឧបសគ្គ

<u>ឱកាស</u>

- តំរូវការទីផ្សារ (កសិផល អនុផលព្រៃឈើ ផលនេសាទ) ។
- សេវាទូរគមនាគមន៍គ្រប់ទីកន្លែង ។
- មានលក្ខណៈងាយស្រួលក្នុងការដឹកជញ្ជូន ផលិតផលកសិផល ។

**<u>ឧបសគ្គ</u> :**

- ទីផ្សារគ្មានស្ថេរភាព ។
- ប្រេងឥន្ធនៈឡើងថ្លៃ ។

# ជំពូក២

# ការវិភាគពី ឧបសគ្គ តម្រូវការ សំរាប់អនាគតនិងសក្ដានុពល

## ២.១ តំបន់សេីប

តំបន់រសេីប គឺជាតំបន់ដែលទាមទារនូវការការពារបន្ថែមនិងជាពិសេស ដោយផ្អែកលើសារៈសំខាន់ ឬ ជីវចំរុះនៃបរិស្ថាន។ ក្នុងឃុំអណ្ដូងថ្មតំបន់ព្រៃលិចទឹកសំបូរទៅដោយជីវៈចំរុះគ្រប់ប្រភេទនិងជាដែនជំរកត្រីពងកូនដែលត្រូវតែរក្សាជាព្រៃលិចទឹកដដែលមិនអាចមានការពង្រីកដីកសិកម្មនៅក្នុងតំបន់នេះបានទេ ។ តំបន់ព្រៃបៃតងត្រូវរក្សាការដុះឡើងវិញនូវ ឈើ អនុផលព្រៃឈើ ដែលរងនូវការបាត់បង់ពីមុនមក ។

## ២.២ ការប្រឈម/ឧបសគ្គ

### ការប្រឈមដោយធម្មជាតិ

កំណើនប្រជាជនជាមធ្យម នៅឃុំអណ្ដូងថ្ម ៥៥នាក់ ក្នុងមួយឆ្នាំ រហូតដល់ឆ្នាំ ២០២២ ចំនួនប្រជាជនសរុបក្នុងឃុំ នឹងឡើងដល់ ៦២២៨ នាក់ ។ ភាពក្រីក្រខ្វះខាត ដីធ្លីធ្វើកសិកម្ម និង ភាពគ្មានការងារធ្វើ ជាកត្តាចំបងបង្កជាសំពាធចំពោះធនធានធម្មជាតិនិងបរិស្ថាន ដែលចាំបាច់ត្រូវពិចារណាទៅលើចំណុចនេះសំរាប់រៀបចំផែនការប្រើប្រាស់ដីនាពេលអនាគត ។ ទំហំជា មធ្យមនៃគ្រួសារនៅក្នុង ឃុំអណ្ដូងថ្ម គឺ ៥ នាក់ នាពេលបច្ចុប្បន្ន ។

### គ្រោះធម្មជាតិ ការរេចរិលនៃធម្មជាតិ

ជារៀងរាល់ឆ្នាំ ឃុំអណ្ដូងថ្មជួបគ្រោះទឹកជំនន់ក្នុងកំឡុងពេលខែកក្កដា-សីហា និងគ្រោះធម្មជាតិដោយខ្យល់ព្យុះខ្លះៗបណ្ដាលអោយខូចខាតសន្ទូងនិងស្តកស្រូវមួយចំនួននៅកំឡុងខែវិច្ឆិកានិងខែធ្នូ ។ មូលហេតុមួយទៀតគឺការកាប់ព្រៃរានធ្វើចំការ ធ្វើអោយមានការហូរច្រោះដីប៉ះពាល់ដល់ជីវចំរុះនិងប្រព័ន្ធអេកូឡូស៊ីនិងជីជាតិដែលតែងតែហូរតាមទឹកភ្លៀងធ្លាក់ចូលស្រែមានការថយចុះធ្វើអោយដីស្រែខ្សោះដោយកង្វះជីធម្មជាតិ ។

### ការប្រឈមដោយ ការអភិវឌ្ឍន៍ ដែលពុំមានចិរភាព

**តំរោងអភិវឌ្ឍន៍ :**

- ការដាំដំណាំដដែលៗលើផ្ទៃដីតែមួយ ការប្រើប្រាស់ជីគីមីមិនត្រឹមត្រូវតាមបច្ចេកទេស ។
- ខ្វះការថែទាំផ្លូវលំ ខូចផ្លូវនៅរដូវវស្សា ទាមទារការជួសជុលរៀងរាល់ឆ្នាំ ។
- ខ្វះទឹកស្អាតប្រើប្រាស់ ។
- ការប្រើប្រាស់ជីគីមី និង ថ្នាំ សំលាប់សត្វល្អិត ខ្វះបច្ចេកទេស ។
- កាប់ព្រៃឈើ ធ្វើចំការ ជាពិសេស ការកាប់ឈើ សំរាប់ធ្វើឡធ្យូង ។
- ការប្រកាន់ជំនឿ ទំនៀមទំលាប់ មិនអោយក្មេងស្រីចូលរៀនរបស់បងប្អូនជនជាតិដើមភាគតិច ( ស្ទួច )
- ទីកន្លែងចាក់សំរាមស្ថិតនៅទីទួលខ្ពស់ជាងលំនៅដ្ឋានប្រជាពលរដ្ឋ បង្កជាផលប៉ះពាល់ ដល់បរិស្ថាន : នៅរដូវប្រាំងជះក្លិនស្អុយ នៅរដូវវស្សាទឹកសំរាមហូរមកជាមួយទឹកភ្លៀងធុំក្លិនមិនល្អ ។

**អំពើអនាធិបតេយ្យ**

- ការកាប់ឈើលក់ និង ធ្វើឡដុតធ្យូង ។
- ការសង់ផ្ទះជាប់ផ្លូវ ។
- ការនេសាទត្រីប្រើឧបករណ៍ខុសច្បាប់ ។
- ការវាយយកថ្មភ្នំលក់ ការជីកកាយយកដីភ្នំ លក់ ។

## ២.៣ កំណត់តម្រូវការនៃការអភិវឌ្ឍន៍ និងគោលដៅយុទ្ធសាស្ត្រឃុំ

**ដោយអំណោយផលធម្មជាតិ**

- ផ្ទៃដីស្រូវវស្សា ២៣.៣១ % ។
- ភ្លៀងធ្លាក់ទៀងទាត់ អាចធ្វើស្រែវស្សាបានរៀងរាល់ឆ្នាំ ។
- ដីមានជីជាតិទទួលបានទិន្នផលមធ្យម ។
- មានប្រភពទឹកធម្មជាតិដែលអាចផ្តល់ សំរាប់ការដាំដំណាំ ចិញ្ចឹមសត្វ និង នេសាទ ។
- មានផ្ទៃដីព្រៃឈើ ( ៥៥.៦៨ % ) ។

**ដោយបច្ចេកវិទ្យាថ្មី**

- ធ្វើស្រែដោយប្រើបច្ចេកទេស ( ភ្ជួរដោយគោយន្ត ........... ) ។
- ជ្រើសរើសពូជ ដាំដំណាំ ដែលផ្តល់ទិន្នផលខ្ពស់ ។
- ការចិញ្ចឹមសត្វ ជ្រូក ដោយបច្ចេកវិទ្យាថ្មី ។

**ដោយគំរោងវិនិយោគ**

ឃុំអណ្តូងថ្ម មិនទាន់មានគំរោងវិនិយោគឯកជន ។

## ២.៤ គំរូវការសំរាប់អនាគត

### ២.៤.១ ប្រជាសាស្ត្រ

#### ២.៤.១.១ អត្រាកំណើន

យោងតាមតារាងខាងលើ បង្ហាញថា ចាប់ពីឆ្នាំ២០០៥ ដល់ ឆ្នាំ២០០៦ ប្រជាពលរដ្ឋមានកំណើន ១% ។ ឆ្នាំ២០០៧ ប្រជាពលរដ្ឋមានកំណើន ១% ឆ្នាំ២០០៨ អត្រា0% ។ ( ប្រភព: ស្ថានភាពភូមិ ឃុំ អណ្តូង ឆ្នាំ២០០៩ )

| ចំនួនគ្រួសារ/ប្រជាជន | ចំនួនគ្រួសារ/ប្រជាជនតាមឆ្នាំ | | | | កំណើនប្រជាសាស្ត្រ | |
|---|---|---|---|---|---|---|
| | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | កំណើនមធ្យម | កំណើន/ឆ្នាំ |
| ចំនួនគ្រួសារសរុប | **៩៣៧** | **១០២៤** | **១០២១** | **១០២៨** | - | - |
| អត្រាកំណើនគ្រួសារ | | ៩% | 0% | ១% | **៣%** | **៣១គ្រួសារ** |
| ចំនួនប្រជាជនសរុប | **៥៣២៨** | **៥៣៨៣** | **៥៤៣៩** | **៥៤៥៨** | - | - |
| អត្រាកំណើនប្រជាជន | | ១% | ១% | 0% | **១%** | **៥៥នាក់** |

### ២.៤.១.២ ការធ្វើចំណោលប្រជាសាស្ត្រ

តារាងការធ្វើចំណោលប្រជាសាស្ត្រ

| ស្ថិតិតាមក្រុមអាយុ | ឆ្នាំ ២០១២ | | ឆ្នាំ ២០១៧ | | ឆ្នាំ ២០២២ | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| អាយុក្រោម ០៥ឆ្នាំ | ៦៨៧ | ៣៣៧ | ៧២០ | ៣៥៣ | ៧៥៣ | ៣៧០ |
| អាយុ ០៥ឆ្នាំ | ២៦៧ | ១២៧ | ២៨០ | ១៣៣ | ២៩៣ | ១៣៩ |
| អាយុពី ៦-១១ឆ្នាំ | ៨៤៣ | ៤០៩ | ៨៨៣ | ៤២៩ | ៩២៤ | ៤៤៨ |
| អាយុពី ១២-១៤ឆ្នាំ | ៤៩២ | ២៣៩ | ៥១៦ | ២៥១ | ៥៤០ | ២៦២ |
| អាយុពី ១៥-១៧ឆ្នាំ | ៤៣៨ | ២០៦ | ៤៥៩ | ២១៦ | ៤៨០ | ២២៦ |
| អាយុពី ១៨-២៤ឆ្នាំ | ៧៦៦ | ៣៨៧ | ៨០៣ | ៤០៦ | ៨៤០ | ៤២៤ |
| អាយុពី ២៥-៦០ឆ្នាំ | ១៨៣១ | ៩៥៣ | ១៩២០ | ៩៩៩ | ២០០៨ | ១០៤៥ |
| អាយុ៦១ឆ្នាំឡើងទៅ | ៣៥៥ | ១៩៣ | ៣៧២ | ២០៣ | ៣៨៩ | ២១២ |
| **ចំនួនប្រជាជនសរុប** | **៥៦៧៨** | **២៨៥១** | **៥៩៥៣** | **២៩៩០** | **៦២២៨** | **៣១២៨** |
| **ចំនួនគ្រួសារសរុប** | **១០៦៩** | | **១១២១** | | **១១៧៣** | |

យោងតាមតារាងវិភាគខាងលើ ប្រជាពលរដ្ឋឃុំអណ្តូងថ្មរយៈពេល ១៥ ឆ្នាំ អាចកើនឡើងចំនួន ៦.២២៨នាក់ ដូច្នេះ សេចក្តីត្រូវការក្នុងការប្រើប្រាស់ដីត្រូវមានកំណើនឡើងមួយក៏រិតថែមទៀត ដូចជាដីស្រែ ចំការ ទីលំនៅស្ថាន សាលារៀន ផ្លូវថ្នល់ ជាដើម ។

### ២.៤.២ តម្រូវការដីសំរាប់លំនៅដ្ឋាន

ដីលំនៅស្ថានក្នុងឃុំអណ្តូងថ្មមានទំហំ ១៤៦.៦៩ ហិកតា តាមការធ្វើនិទស្សន៍ ឃើញថារហូតដល់ឆ្នាំ២០២២ ប្រជាជនកើនឡើងចំនួន៦.២២៨នាក់ ដូច្នេះតម្រូវការដីសង់លំនៅដ្ឋានអាចកើនឡើងដល់១៦៦ហិកតាបើគិតតាមឆ្នាំគោល២០០៨ ក្នុងប្រជាជន១នាក់ មានដីសង់លំនៅដ្ឋាន ស្មើនឹង ៣៧.២១អា ។

តម្រូវការដីលំនៅដ្ឋាននឹងកើនឡើង ហេតុនេះដើម្បីកុំអោយមានការប៉ះពាល់ដល់ដីបង្កបង្កើនផលស្រូវវស្សា ប្រជាពលរដ្ឋគួរពង្រីកដីលំនៅដ្ឋាននៅលើប្រភេទ ដីចំការវិញ ( ដែលស្ថិតនៅខាងលិចថ្នល់ ) ។

### ២.៤.៣ តម្រូវការដីសំរាប់កសិកម្ម

**តម្រូវការស្បៀង :**

យោងតាមការឯកសារស្ថានភាពឃុំឆ្នាំ២០០៧-២០០៨ក្នុងមនុស្ស១នាក់ត្រូវការ ស្រូវ៦០៣គីឡូក្រាមក្នុង ១ឆ្នាំ ដូច្នេះសំរាប់ក្នុងឆ្នាំ២០២២ តម្រូវការស្រូវសំរាប់ឃុំទាំងមូលមានប្រមាណ៣.៧១៨ តោន ។

**តម្រូវការផ្ទៃដីស្រូវវស្សា :**

ដោយកំណើនប្រជាពលរដ្ឋកាន់តែកើនឡើង ដីកសិកម្មនឹងត្រូវពង្រីកបន្ថែមចំនួន២២១.១៥ហិកតាដោយគិតតាមឆ្នាំគោលមានចំនួន១.៧១០,៨៨ហិកតា សំរាប់ប្រជាពលរដ្ឋចំនួន៥.៤៥៨នាក់ ។ តាមលក្ខណៈភូមិសាស្ត្រ និងប្រភេទដីស្រែឃុំអណ្តូងថ្មមិនអាចធ្វើការពង្រីកដីស្រែបន្ថែមទៀតបានដោយសារខាងលិចទល់នឹងដីលំនៅដ្ឋាន ខាងកើតទល់នឹងតំបន់ព្រៃលិចទឹក ។ ហេតុនេះហើយដើម្បីរក្សានូវសន្តិសុខស្បៀងនៅឆ្នាំ២០២២ ប្រជាពលរដ្ឋគួរធ្វើស្រែបង្កើនរដូវ ។ ការបង្កើនផលរដូវប្រាំងមិនអាចធ្វើបានទេ ដោយសារប្រភេទដីស្រែជាដីទទួលនូវឥទ្ធិពលពីសមុទ្រមានកំរិតpH=4នៅរដូវប្រាំងហើយបរិមាណផ្គត់ផ្គង់ទឹកមិនគ្រប់គ្រាន់។ ជាក់ស្តែងនៅក្នុងឃុំមានអាងស្តុកទឹកតែមួយទំហំ៦១០ហិកតា ចំណុះស្តុកទឹកបានតែ ២៥៨.៨៧០ម៣ សំរាប់ប្រើប្រាស់ជាមួយឃុំសំរុង ។

បើតាមអ្នកបច្ចេកទេសដំណាំស្រូវបានឱ្យដឹងថា ក្នុងស្រូវប្រាំង១ហិកតា ចាប់ពីធ្វើការសាបព្រោះ ដកស្ទូងច្រូតកាត់ត្រូវការទឹកចំនួន១០.០០០ម៣ ដូច្នេះអាងស្តុកទឹកអាចបំរើអោយផ្ទៃដីស្រូវប្រាំងតែ២៥.៨៨៧ហិកតាសំរាប់ពីរឃុំ (អណ្តូងថ្មនិងសំរុង) ដោយមិនគិតពីការប្រើប្រាស់នៅលើដំណាំរួមផ្សំ និងការប្រើប្រាស់ផ្សេងៗទៀតឡើយ ។ បើប្រៀបធៀបនឹងតំរូវការដីបន្ថែម២២១.១៥ហិកតាថែមទៀតនោះ យើងដូចខ្វះទឹកសំរាប់ធ្វើស្រែប្រាំងចំនួន២០៨.២០៦៥ម៣ បន្ថែម ហេតុនេះប្រជាពលរដ្ឋមិនអាចធ្វើស្រែប្រាំងបានទេ ។

ផ្អែកលើការវិភាគខាងលើដើម្បីបំពេញបាននូវតម្រូវការស្បៀងសំរាប់ឆ្នាំ២០២២ ប្រជាកសិករអាចមានលទ្ធភាពតែមួយគត់ គឺ ស្រែ២ដងក្នុងរដូវវស្សា តាមរយៈការប្រើប្រាស់ពូជស្រូវស្រាល ដូចជាស្រូវសែនពិដោរ ជាដើម។

**<u>តម្រូវការដីចំការ</u>** : ផ្ទៃដីចំការនៅឃុំអណ្តូងថ្មមានទំហំ៥២៥.៩០៤ហិកតា ។ នៅឆ្នាំ២០០៨ប្រជាពលរដ្ឋដាំដំណាំរួមផ្សំបានតែបន្តិចបន្តួចតែប៉ុណ្ណោះដូច្នេះផ្ទៃដីនៅទំនេរមានច្រើន ដោយសារការប្រើប្រាស់ដីចំការនៅឃុំមិនទាន់អស់លទ្ធភាពនៅឡើយ ហេតុនេះសំរាប់ឆ្នាំ ២០២២ ឃុំមិនបានគ្រោងពង្រីកដីសំរាប់ចំការដំណាំឡើយ ។

សំរាប់ផែនការរយៈពេល១៥ឆ្នាំ ក្រុមប្រឹក្សាឃុំបានលើកជាសកម្មភាពមួយចំនួន :

- ដាំមនចំនួន ៦៣ហិកតា ។
- កសិដ្ឋានចិញ្ចឹមគោ ១៧០ហិកតា ។
- សិប្បកម្មខ្នាតតូច ៦៣ហិកតា ។
- ដាំអំពៅ ២០ហិកតា ។
- លំនៅស្ថាន ២០ហិតា ។
- ស្រះចិញ្ចឹមត្រី ៥ហិកតា ។

## ២.៤.៤ <u>តម្រូវការសម្រាប់កិច្ចការពារបរិស្ថាន និង ធនធានធម្មជាតិ</u>

**<u>ដីព្រៃភ្នំ</u>**: សព្វថ្ងៃប្រភេទឈើកំពុងដុះឡើងវិញ មានគគីខ្សាច់ ស្រឡៅ គគីភ្នង ចំបក ព្រីង បាយ ប្រវាំង.. និងមានសត្វព្រៃមួយចំនួនទៀតដូចជាជ្រូកព្រៃស្វា តូច ទន្សាយ ឈ្លូស អាញ្ញ ។ល ។និងមានប្រជាពលរដ្ឋមួយចំនួនឡើងភ្នំដើម្បីរកផ្តៅជ័រល្វីង និងអនុផលព្រៃឈើផ្សេងៗទៀតដើម្បីលក់ចិញ្ចឹមជីវិត ។ ដើម្បីរក្សាធនធានទាំងនេះអោយបានគង់វង្ស ប្រជាពលរដ្ឋគួរតែបង្កើតជាសហគមន៍គ្រប់គ្រងនិងប្រើប្រាស់ធនធានទាំងនេះប្រកបដោយនិរន្តរភាព។

**ដីព្រៃលិចទឹក** : ដីព្រៃលិចទឹកស្ថិតនៅតាមបណ្តោយឆកវាលវិញជាប្រភេទដីល្បប់សមុទ្រមានរុក្ខជតិដុះជាច្រើនប្រភេទដូចជា កោងកាង ប្រសាក់ ក្រញូីប អំពូ អំពា អំពូក្រហម ប្រង់ ។ល។ និងជីវៈចំរុះជាច្រើនប្រភេទដូចជាបក្សីមច្ឆាសិប្បីសត្វនិងប្រភេទល្មូនជាដើម ។ដោយសារមានការយកចិត្តទុកដាក់ពីរដ្ឋបាលជលផលនិងសហគមន៍នេសាទការពារព្រៃលិចទឹក ព្រៃនេះនៅរក្សាបានទ្រង់ទ្រាយដើមទោះបីជាមានការខូចខាតបន្តិចបន្តួចដោយសារការកាប់ដើម្បីសាងសង់លំនៅស្ថាន ធ្វើអូទូក និងការប្រកបរបរចិញ្ចឹមជីវិតដោយការកាប់អុសលក់ នេសាទត្រី រកងាវ។ ដើម្បីរក្សាបាននូវបរិស្ថានអោយបានល្អ សហគមន៍ត្រូវបង្កើតជាតំបន់ដែនជំរកសុវត្ថិភាព ។

### ២.៩.៥ តម្រូវការដីសំរាប់ហេដ្ឋារចនាសម្ព័ន្ធ

#### ២.៩.៥.១ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍និងប្រព័ន្ធសង្គម

សំរាប់ហេដ្ឋារចនាសម្ពន្ធ័ផ្សេងៗនៅក្នុងឃុំ យើងបានបញ្ចូលទៅក្នុងតម្រូវការដីសង់លំនៅស្ថានរួចហើយក្នុងនោះមាន

| ហេដ្ឋារចនាសម្ពន្ធ័ | ចំនួនក្នុងឆ្នាំនេះ | ចំនួន ១៥ឆ្នាំក្រោយ | បំរែបំរួល |
|---|---|---|---|
| ថ្នាក់មត្តេយ្យ | ២ បន្ទប់ | ៦ បន្ទប់ | ៤ បន្ទប់ |
| ថ្នាក់បឋមសិក្សា | ១០ បន្ទប់ | ៣៤ បន្ទប់ | ២៤ បន្ទប់ |
| ថ្នាក់អនុវិទ្យាល័យ | ៤ បន្ទប់ | ១១ បន្ទប់ | ៧ បន្ទប់ |
| អណ្តូងទឹក | ៨១១ | ១១១១ | ៣០០អណ្តូង |
| ប៉ុស្តិ៍នគរបាល | 0 | ១ | ១ ខ្នង |
| សាលាសង្កាត់ | 0 | ១ | ១ ខ្នង |

**ហេដ្ឋារចនាសម្ពន្ធ័គមនាគមន៍ និងប្រព័ន្ធស្រោចស្រព**

ផ្អែកតាមសភាពជាក់ស្តែងឃុំអណ្តូងថ្មមានប្រព័ន្ធគមនាគមន៍បានធ្វើរួចរាល់ចំនួន ១១ ខ្សែ ផ្លូវមិនទាន់បានកសាងមានចំនួន ២៣ ខ្សែ ក្រុមប្រឹក្សាឃុំបានលើកជាផែនការសំរាប់កសាងបន្ថែមក្នុងរយៈពេល ១៥ឆ្នាំ មាន :

**ក ,ខាងកើតថ្នល់ :**

- ខ្សែទី២ : ផ្លូវអាត្រាក់ចាស់មានប្រវែង២.៨00ម៉ែត្រពីផ្លូវជាតិលេខ៤ដល់ជើងភ្នំ( ជាផ្លូវគ្រួសក្រហម ) ។

- ខ្សែទី៣ : ពីផ្លូវជាតិលេខ៤ដល់កន្លែងកប់ខ្មោចមានប្រវែង៥៤0ម៉ែត្រ (គ្រោងជាផ្លូវគ្រួសក្រហម ) ។

- ខ្សែទី៤:ផ្លូវរទេះចាប់ផ្លូវជាតិលេខ៤ដល់ទំនប់ទឹកភូមិត្រពាំងស្អុយ១ប្រវែង៥00ម៉ែត្រ( គ្រោងជាផ្លូវគ្រួសក្រហម ) ។

- ខ្សែទី៥ : ពីផ្លូវជាតិលេខ៤ដល់កន្លែងកប់ខ្មោចទួលគគីមានប្រវែង ៥00ម៉ែត្រ( គ្រោងផ្លូវគ្រួសក្រហម )

- ខ្សែទី៨ : ពីផ្លូវជាតិលេខ៤ ដលផ្ទះហេង ង៉ុន ប្រវែង ២00ម៉ែត្រ ( គ្រោងជាផ្លូវគ្រួសក្រហម ) ។

- ខ្សែទី៩ : ផ្លូវលំ ភឿន ចេង មានប្រវែង ១០០០ម៉ែត្រ ទល់ផ្លូវអ៊ុកសីហា( គ្រោងជាផ្លូវគ្រួសក្រហម ) ។

- ខ្សែទី១០:ផ្លូវលំក្បាលស្ពានអូរត្រាវពីផ្លូវជាតិលេខ៤ដល់ផ្ទះឃឹម-ង៉នមានប្រវែង៣១០ម៉ែត្រ( គ្រោងជាផ្លូវគ្រួសក្រហម ) ។

- ខ្សែទី១៣: ផ្លូវលំភូមិតាង៉ែត មានប្រវែង ៣៧០ម៉ែត្រ ពីផ្លូវជាតិលេខ៤ ( គ្រោងជាផ្លូវគ្រួសក្រហម )

- ខ្សែទី១៥ : ផ្លូវលំសុខ ប្រុស មានប្រវែង ១០០ម៉ែត្រ ពីផ្លូវជាតិលេខ៤ ដល់ផ្ទះខៀវ ចាន ( គ្រោងជាផ្លូវគ្រួសក្រហម )

**ខ. ខាងកើតផ្លូវលំ :**

-ខ្សែទី២:ផ្លូវលំផ្ទះតាឈួនមានប្រវែង៧៣០ម៉ែត្រទល់នឹងកំពង់តាណុប( ធ្វើបន្ត១៥០ម៉ែត្រទល់នឹងវាលស្រែ

- ខ្សែទី៨ : ផ្លូវរទេះ ប្រវែង ២០០ម៉ែត្រ ( គ្រោងជាផ្លូវគ្រួសក្រហម )

- ខ្សែទី៩ : ផ្លូវជាតិលេខ៤ ទល់ផ្ទះហេង ប៉ាន់ ប្រវែង ២៥០ម៉ែត្រ ( គ្រោងជាផ្លូវគ្រួសក្រហម ) ។

- ខ្សែទី១៤:ផ្លូវលំស្ពានអូត្រាវខាងត្បូងមានប្រវែង៧៣០ម៉ែត្រចាប់ពីផ្លូវជាតិលេខ៤ដល់ផ្ទះសាន់រ៉េមគ្រោងផ្លូវគ្រួសក្រហម )

- ខ្សែទី១៥ :ផ្លូវលំស្ពានអូត្រាវខាងជើងមានប្រវែង៤៥០ម៉ែត្រចាប់ពីផ្លូវជាតិលេខ៤ដល់ផុតផ្ទះប្រជាពលរដ្ឋ ( គ្រោងធ្វើ បន្ថែម១៥០ម៉ែត្រ )

- ខ្សែទី១៦ : ផ្លូវលំផ្ទះតុ សាន់ មានប្រវែង ៦៤៨ម៉ែត្រ ទល់ផ្ទះតុ ឡៃ ( គ្រោងជាផ្លូវគ្រួសក្រហម )

- ខ្សែទី១៧ : ផ្លូវលំផ្ទះសើម៉ើត ប្រវែង ៣៤០ម៉ែត្រ ទល់ផ្ទះ ឃឹម ប៊ិយ ( គ្រោងធ្វើបន្ត៣០០ ម៉ែត្រ )

- ខ្សែទី១៨ : ផ្លូវលំព្រំប្រទល់អូរត្រាវប្រវែង ៣៥០ម៉ែត្រទល់ផ្ទះឡេះនាង ( គ្រោងធ្វើបន្ត ៣០០ ម៉ែត្រ )

- ខ្សែទី១៩:ផ្លូវលំទទឹងថ្ងៃផ្ទះតុម៉ាត់ទល់ប្រឡាយអូរជញ្ជ្រោងមានប្រវែង២២៩៥ម៉ែត្រ ( គ្រោងធ្វើ២៥០ម)

- ខ្សែទី២៣ : ពីផ្ទះឃឹម ឡាង ទល់ នឹងលូជ្រុង ប្រវែង ១៥០០ម៉ែត្រ ( គ្រោងជាផ្លូវគ្រួសក្រហម )

- ខ្សែទី២៤: ពីផ្លូវទទឹងផ្ទះគឹម ម៉ាត់ ប្រវែង ២០០ម៉ែត្រ ( គ្រោងជាផ្លូវគ្រួសក្រហម )

- ខ្សែទី២៥:ពីផ្លូវទទឹងផ្ទះ ឡឹប សុប ទល់ ផ្ទះតុ យ៉ឹប ប្រវែង ៣០០ម៉ែត្រ ( គ្រោងជាផ្លូវគ្រួសក្រហម )

- ខ្សែទី២៦: ពីផ្លូវជាតិលេខ៤ទល់សារ៉ាវអូរត្រាវ ប្រវែង ១៧០ម៉ែត្រ ( គ្រោងជាផ្លូវគ្រួសក្រហម )

- ខ្សែទី២៧ ពីផ្លូវជាតិលេខ៤ទល់នឹងអ៊ុង សុះ ប្រវែង ២០០ម៉ែត្រ ( គ្រោងជាផ្លូវគ្រួសក្រហម )

**.ប្រព័ន្ធស្រោចស្រព :**

ចំពោះឃុំអណ្តូងថ្ម ផ្នែកប្រព័ន្ធស្រោចស្រពមានការខូចខាតស្ទើរទាំងស្រុង ហេតុដូច្នេះហើយដែលបណ្តាលអោយការបង្កបង្កើនផល ទាំងដំណាំរួមផ្សំនិងដំណាំស្រូវមិនទទួលបានទិន្នផលខ្ពស់ ។ ដើម្បីអនុវត្តនីបាននូវផ្នែកការផលិតកម្មដំណាំឧស្សាហកម្មនិងដំណាំស្បៀងរយៈពេល១៥ឆ្នាំខាងមុខយើងគួររៀបចំប្រព័ន្ធស្រោចស្រពអោយបានមុន យោងតាមការវិភាគលើតម្រូវការខាងប្រព័ន្ធស្រោចស្រពរយៈពេល១៥ឆ្នាំមាន :

- កសាងទ្វារអាងស្តុកទឹកឃុំអណ្តូងថ្ម និង សំរ៉ុង
- ជីកប្រឡាយទទឹង គិតចាប់ពីប្រឡាយនីហារមកទល់នឹងព្រំប្រទល់ទួល ទទឹងមានប្រវែង ៣៤០០ម៉ែត្រ
- ស្តារព្រែកទឹកស្ទាច់ទេរ ប្រវែង ២៥០០ម៉ែត្រ
- ស្តារព្រែកផ្ទះតាយេប ប្រវែង ៤៥០០ម៉ែត្រ
- ស្តារព្រែកឃុំ ប្រវែង ២០០០ម៉ែត្រ
- ស្តារព្រែកកូនកុក ប្រវែង ៣០០០ម៉ែត្រ
- ស្តារព្រែកបន្ទាយប្រើយ៍ ប្រវែង ៥០០០ម៉ែត្រ
- ស្តារព្រែកតាសេក ប្រវែង ៣០០០ម៉ែត្រ
- ស្តារព្រែកឃ្លួងធំ ប្រវែង ៧០០០ម៉ែត្រ

### ២.៤.៥.២ តម្រូវការដីសាលារៀន

ផ្ទៃដីសំរាប់សាងសង់សាលារៀនក្នុងឆ្នាំ២០០៨មានទំហំ១,៧៥ហិកតា ។ ដូច្នេះដីសំរាប់សាង សង់យើងមានរួចហើយយើងគ្រាន់តែសាងសង់បន្ទប់រៀនបន្ថែមទៀតប៉ុណ្ណោះ ។ សំរាប់ផែនការ១៥ឆ្នាំខាងមុខ តម្រូវការបន្ទប់រៀនបន្ថែម ដូចខាងក្រោមនេះ :

| ប្រភេទសាលា | នៅឆ្នាំ ២០១២ | | | នៅឆ្នាំ ២០១៧ | | | នៅឆ្នាំ ២០២២ | | |
|---|---|---|---|---|---|---|---|---|---|
| | កុមារ | សាលា | បន្ទប់ | កុមារ | សាលា | បន្ទប់ | កុមារ | សាលា | បន្ទប់ |
| ថ្នាក់មត្តេយ្យសិក្សា | ២៦៧ | ០ | ១ | ២៨០ | ០ | ២ | ២៩៣ | ០ | ១ |
| ថ្នាក់បឋមសិក្សា | ៨៤៣ | ០ | -២ | ៨៨៣ | ១ | ៧ | ៩២៤ | ៣ | ១៧ |
| ថ្នាក់អនុវិទ្យាល័យ | ៤៩២ | ០ | ១ | ៥១៦ | ១ | ៦ | ៥៤០ | ០ | -១ |
| ថ្នាក់វិទ្យាល័យ | ៤៣៨ | ១ | ៤ | ៤៥៩ | ០ | ០ | ៤៨០ | ១ | ៥ |
| ... | | | | | | | | | |

**សំគាល់:**

- កត្តាសន្មត់: សាលា ០១ ខ្នង មានចំនួន ០៥ បន្ទប់ សិស្សក្នុង ០១ ថ្នាក់ មានចំនួន ៥០ នាក់ ហើយ ក្នុង ០១ ថ្ងៃ រៀនចំនួន ០២ វេន

### ២.៤.៥.៣ សេវាកម្មសុខភាព និងការផ្គត់ផ្គង់ទឹកស្អាត

**សេវាកម្មសុខភាព** : មណ្ឌលសុខាភិបាលនៅឃុំអណ្តូងថ្មមាន១កន្លែង មាន១អគារមានទំហំដី ៣១អា។ រយៈពេល១៥ឆ្នាំកំនើនប្រជាពលរដ្ឋមានអត្រាកើនឡើងតែ៦.២២៨នាក់បើប្រៀបធៀបឆ្នាំគោលមានតែ៥៤៥៨នាក់។

កំណើននេះតិចតួចនៅឡើយ គឺមិនទាន់ត្រូវការសាងសង់បន្ថែមមណ្ឌលសុខភាព ។ មណ្ឌលសុខភាពចាស់អាចបំរើសេចក្តីត្រូវការរបស់ ប្រជាជនបានគ្រប់គ្រាន់រហូតដល់ឆ្នាំ ២០២២ ។

**ការផ្គត់ផ្គង់ទឹកស្អាត** : ការប្រើប្រាស់ទឹកស្អាតនៅឃុំអណ្តូងថ្មនៅមានកំរិតទាបនៅឡើយដោយសព្វថ្ងៃអណ្តូងនៅក្នុងឃុំមានចំនួនតែ៨១១អណ្តូងតែប៉ុណ្ណោះ ។ តម្រូវការរយៈពេល១៥ឆ្នាំខាងមុខត្រូវការអណ្តូងទឹកចំនួន ៣00 បន្ថែមទៀត ដើម្បីបំរើសេចក្តី ត្រូវការរបស់ប្រជាជនបានគ្រប់គ្រាន់ ។

# ជំពូក៣

# ផែនការប្រើប្រាស់ដី ពេលអនាគតឆ្នាំ២០០៩-២០២២

## ៣.១ ស្ថានភាពដី សក្តានុពលដី និង តម្រូវការដី

### ៣.១.១ ស្ថានភាពដីទូទៅ និងសក្តានុពល

តាមស្ថានភាពជាក់ស្តែង ដីឃុំអណ្តូងថ្ម ត្រូវបានចែកចេញជាពីរតំបន់សំខាន់ៗ :

-តំបន់ខ្ពស់រាបនិងភ្នំ: ជាតំបន់ដែលគ្របដណ្តប់ដោយព្រៃឈើ លាតសន្ធឹង ខាងលិចផ្លូវជាតិលេខ៤ (រហូតដល់ឃុំទំនប់រលក) ទល់នឹងព្រំប្រទល់ ឃុំទំនប់រលក ស្រុកស្ទឹងហាវ ។

-តំបន់វាលរាប:ជាតំបន់កសិកម្មលាយជាមួយលំនៅដ្ឋាន ដែលគ្របដណ្តប់ចាប់ពីប៉ែកខាងកើតផ្លូវជាតិលេខ ៤ ទល់នឹង តំបន់ព្រៃលិចទឹកឆកសមុទ្រវាលរេញ ។

-តាមការផ្តល់ទិន្នន័យ អំពីផលិតភាពរបស់ដីថ្នាក់ជាតិ បានបង្ហាញអោយឃើញថា ឃុំអណ្តូងថ្ម ស្ថិតក្នុងតំបន់ ដីដែលមានផលិតភាពទាប ។ ផ្ទៃដីសំរាប់ប្រកបរបរកសិកម្ម បានទទួលទិន្នផល ២,៣ តោន/ហិកតា (ស្រូវវស្សា)។ ប៉ុន្តែតំបន់នេះមានអំណោយផលពីផ្ទៃដីព្រៃឈើប្រមាណ២៣.៩៥១.៩៣៣ហិកតា ដែលជាអាចទាញទឹកភ្លៀងគ្រប់គ្រាន់សំរាប់ទ្រទ្រង់ប្រព័ន្ធអេកូឡូស៊ី ។

### ៣.១.២ តម្រូវការដីតាមប្រភេទ

| ការប្រើប្រាស់ដីធ្លី | ក្រឡាផ្ទៃឆ្នាំនេះ(ហិកតា) | ក្រឡាសំរាប់ផ្ទៃ១៥ឆ្នាំខាងមុខ (ហិកតា) | បំរែបំរួល (ហិកតា) |
|---|---|---|---|
| ដីលំនៅដ្ឋានភូមិ | ១៤៦.៦៩ | ១៨២.៨៩ | ៣៦.២០ |
| ដីកប់ខ្មោច | ២.២៩ | ២.២៩ | 00.00 |
| ស្រូវវស្សា | ១៦១៧.00 | ១៦១៧.00 | 00.00 |
| ដីស្រែជាមួយភូមិ | ៩៤.២៧ | ៨១.៤៦ | -១២.៨១ |
| ចំការដំណាំ | ៥២៣.៦៥ | ២៤៥.៣១ | -២៧៨.៣៤ |
| ព្រៃដុះឡើងវិញ | ២៣៥៥.១៥ | ១៤៣៣.៥៥ | -៩២១.៦ |
| ព្រៃកោងកាងស្តើង | ១០៧.២៧ | ១០៧.២៧ | 00.00 |
| វាលស្មៅ | ៣.៧៨ | ៣.៧៨ | 00.00 |
| ចំការបោះបង់ដុះស្មៅ | ២៥.៥៥ | 00.00 | -២៥.៥៥ |
| ទន្លេ ស្ទឹង អូរ | ១៤.៥៥ | ១៤.៥៥ | 00.00 |
| សមុទ្រ | ៣.៨៨ | ២.២៤ | -១.៦៤ |
| ផ្ទាំងថ្មដុះពីដី | ១.៣៤ | ១.៣៤ | 00.00 |

| | | | |
|---|---|---|---|
| ហេដ្ឋារចនាសម្ព័ន្ធ | 00.00 | ៣២.៤១ | ៣២.៤១ |
| សហគមន៏ព្រៃឈើ | 00.00 | ៩៨៩.៦០ | ៩៨៩.៦០ |
| ស្រែចិញ្ចឹមត្រី ឬបង្គា | 00.00 | ១២.២៨ | ១២.២៨ |
| កសិដ្ឋាន | 00.00 | ១៦៩.៧៥ | ១៦៩.៧៥ |
| **សរុប** | ៤៨៩៥.៤២ | ៤៨៩៥.៤២ | |

## ៣.២ ការបែងចែកដីតាមតម្រូវការប្រើប្រាស់

### ៣.២.១ ការវិភាគអន្តរអំពើ

**ក. ការអភិរក្សតំបន់ភ្នំ**

- ផលវិជ្ជមាន : រក្សាលំនឹងអេកូឡូស៊ី ថែរក្សាបាននូវជីវចំរុះ ជីវភាពប្រជាជននឹងត្រូវបានកែលំអតាមរយៈទេសចរណ៏ធម្មជាតិសំរាប់រយៈពេលវែង ។

- ផលអវិជ្ជមាន: បាត់បង់ចំណូលប្រចាំថ្ងៃពីការទាញយកផល និង អនុផលព្រៃឈើ ។

**ខ. ការអភិរក្សតំបន់ព្រៃលិចទឹក**

- ផលវិជ្ជមាន: បង្កើនផលត្រី រក្សាប្រព័ន្ធអេកូឡូស៊ី ។

- ផលអវិជ្ជមាន: បាត់បង់មុខរបរនេសាទនៅក្នុងព្រៃដែលដាក់ជាតំបន់អភិរក្ស, ខ្វះដីធ្វើស្រែចំការ ។

### ៣.២.២ ផែនទីប្រើប្រាស់ដីអនាគត

ផែនទីប្រើប្រាស់ដីអនាគតគូសបង្ហាញពីការគ្រោងពង្រីក ដីលំនៅដ្ឋាន សហគមន៏ព្រៃឈើ និង ផែនការដែលត្រូវអភិវឌ្ឍន៏ នៅពេលអនាគត ដែលមានប្រភពនៃការប្រើប្រាស់ដី ដូចខាងក្រោម:

- ដីលំនៅដ្ឋានភូមិ
- ហេដ្ឋារចនាសម្ព័ន្ធ
- ដីសហគមន៏ព្រៃឈើ
- ស្រែចិញ្ចឹមត្រីឬបង្គា
- កសិដ្ឋាន




### ៣.២.៣.ការបរិយាយពីការប្រើប្រាស់ក្បាលដី

### ១. ដីលំនៅដ្ឋាន

**ក្បាលដី F1200-01 = 28.70ha**

ដីលំនៅដ្ឋាននេះមានទំហំ ២៨.៧០ហិកតា បានមកពីការប្រែក្លាយដីចំការដំណាំ ២៨.៧០ហិកតា សព្វថ្ងៃជាប្រភេទដីរេចរិលមិនអាចបំរើការលើវិស័យណាមួយបាន ។ មូលហេតុខាងលើទើបក្រុមប្រឹក្សាឃុំ សង្កាត់បានប្រើដីនេះសំរាប់សង់លំនៅដ្ឋាននៅក្នុងអំលុងពេល១៥ឆ្នាំខាងមុខ។

**ក្បាលដី F1200-02 =7.50ha**

ដីលំនៅដ្ឋាននេះមានទំហំ ៧.៥០ហិកតា បានមកពីដីចំការដំណាំ២.២៩ហិកតា ដីចំការបោះបង់ដុះស្មៅ ២.០០ហិកតានិងដីស្រែវស្សា៣.២១ហិកតា ដោយដីទាំងបីប្រភេទនេះសព្វថ្ងៃជាប្រភេទដីរេចរិល មិនអាចបំរើការលើវិស័យណាមួយបានទើបក្រុមប្រឹក្សាឃុំសង្កាត់បាន ប្រើដីនេះសំរាប់សង់លំនៅដ្ឋាននៅក្នុងអំលុងពេល១៥ឆ្នាំខាងមុខ ។

## ២. ហេដ្ឋារចនាសម្ព័ន្ធ

**ក្បាលដី F1300-01 =28.70ha**

ដីនេះមានទំហំ៣២.៣ហិកតា បានមកពីដីចំការដំណាំទំហំ២២.៧០ហិកតា ដីស្រែវស្សា៩.៦០ហិកតា ដែលបច្ចុប្បន្នត្រូវបានបោះបង់ចោលមិនបង្កបង្កើនផល ។បច្ចុប្បន្នឃុំអណ្ដូងថ្មនៅមានការខ្វះខាតនៅគំរោងវិនិយោគលើវិស័យឧស្សាហកម្ម ដែលជាវិស័យមួយអាចរកការងារអោយប្រជាពលរដ្ឋធ្វើបានច្រើនហើយក៏អាចជួយកាត់បន្ថយ នូវភាពក្រីក្ររបស់ប្រជាពលរដ្ឋផងដែរហេតុនេះទើបក្រុមប្រឹក្សាឃុំសំរេចលើកផែនការទាក់ទាញអ្នកវិនិយោគមកកសាងរោងចក្រខ្នាតតូចមួយនៅទីនេះ ។

## ៣. សហគមន៍ព្រៃឈើ

**ក្បាលដី F3700-01 =989.60ha**

ដីនេះមានទំហំ៩៨៩.៦០ហិកតា បានមកពីដីចំការដំណាំទំហំ ៦៨ .០០ ហិកតា ព្រៃដុះឡើងវិញ ៩២១.៦០ ហិកតា ដែលបច្ចុប្បន្នទទួលរងនូវភាពរេចរិលនិងការកាប់ទន្រ្ទាន ក្រុមប្រឹក្សាឃុំបានប្រជុំនិងមានផែនការរៀបចំសំណើទៅរដ្ឋបាលព្រៃឈើដើម្បីបង្កើតជាសហគមន៍ព្រៃឈើនិងជួយកាត់បន្ថយនូវជីវភាពកង្វះខាតរបស់ប្រជាពលរដ្ឋក្នុងឃុំ ។

## ៤. ស្រែចិញ្ចឹមត្រីឬបង្កា

**ក្បាលដី F5400-01 =10.60ha**

ដីនេះមានទំហំ ១០.៦០ ហិកតា បច្ចុប្បន្នជាដីចំការបោះបង់ចោលមានទំហំ ១០,៦៤ ហិកតា ក្រុមប្រឹក្សាឃុំបានកំណត់យកទីតាំងនេះសំរាប់ធ្វើជាស្រះចិញ្ចឹមត្រីដែលមានលក្ខណៈគ្រួសារ ជាពិសេសទៀតដីនេះសមស្របដោយមានប្រភពទឹក និងបង្កើនជីវភាពប្រជាពលរដ្ឋឱ្យកាន់តែមានជីវីភាពប្រសើរឡើង ។

**ក្បាលដី F5400-02 =1.64ha**

យោងតាមអនុសាស្រ្តដ៏ថ្លៃថ្លារបស់សម្ដេចនាយករដ្ឋមន្រ្តី ដែលបានអនុញ្ញាតអោយប្រជាពលរដ្ឋចិញ្ចឹមត្រីនៅក្នុង ដៃព្រៃ និងស្ទឹង ទិសដៅទៅអនាគត ឃុំសំរេចយកផ្ទៃទឹកចំនួន ១,៦៤ ហិចតា សំរាប់ការចិញ្ចឹមត្រីក្នុងបែរដែលស្ថិតនៅច្រកសមុទ្រវាលរេញ ។

## ៥. កសិដ្ឋាន

**ក្បាលដី F7200-01 =169.75 ha**

ដីនេះមានទំហំ១០.៦០ហិកតា បច្ចុប្បន្នជាដីចំការបោះបង់ចោលមានទំហំ ២,០០ហិកតា ដីចំការដំណាំទំហំ ១៤៦.០០ហិកតា និងដីព្រៃដុះឡើងវិញ០.២០ហិកតា ក្រុមប្រឹក្សាឃុំបានកំណត់ទិសដៅជាយុទ្ធសាស្រ្តយកទីតាំងនេះសំរាប់ចិញ្ចឹមសត្វពាហនៈ ដូចជា គោ ក្របី ពពែ ។

# សេចក្តីសន្និដ្ឋាននិងអនុសាសន៍លើផែនការប្រើប្រាស់ដី

## សន្និដ្ឋាន

យោងតាមការវិភាគខាងលើបានបង្ហាញឱ្យឃើញនូវការប្រឈម និងឧបសគ្គនានា ដែលធ្វើអោយរាំងស្ទះដល់ដំណើរការអភិវឌ្ឍន៍កាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ដោយសារការប្រើប្រាស់ដីមិនមានលក្ខណៈសមស្របទៅតាមបច្ចេកទេស ការប្រើប្រាស់ធនធានធម្មជាតិហួសកំរិត កំណើនប្រជាពលរដ្ឋកាន់តែកើនឡើងជាលំដាប់ ។ម្យ៉ាងវិញទៀត ការប្រើប្រាស់ដីគ្មានផែនការច្បាស់លាស់ដូចជាការសាងសង់លំនៅដ្ឋាននៅលើដីស្រែបណ្តាលអោយបាត់បង់ដីបង្កើនផលស្រូវវស្សា ។ ការកាប់រានយកដីព្រៃលិចទឹកក។ដូចជាដីព្រៃភ្នំយកជាកម្មសិទ្ធិ ការទុកដីឱ្យនៅទំនេរមិនបង្កបង្កើនផល ប្រការទាំងនេះហើយជាផលប៉ះពាល់ដល់សេដ្ឋកិច្ចជាតិនិងប្រជាពលរដ្ឋក្នុងភូមិផ្ទាល់ ។

## អនុសាសន៍:

១.ក្រុមប្រឹក្សាឃុំអណ្តូងថ្ម បានដាក់បញ្ចូលសកម្មភាពខាងក្រោមនេះ ទៅក្នុងកម្មវិធីវិនិយោគឃុំសង្កាត់:

- ការធ្វើស្រែវស្សាឱ្យបានពីរដងក្នុងមួយរដូវ ។
- បង្កើនការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ ។
- ជីកស្រះចិញ្ចឹមត្រី និងចញ្ចឹមត្រីក្នុងបែរ ។
- ការដាំដំណាំរួមផ្សំ និងដំណាំឧស្សាហ៏កម្មឱ្យអស់លទ្ធភាពដីដែលមាន ។
- ការរក្សាធនធានធម្មជាតិ ដែលមាននៅក្នុងឃុំ ។
- សង់សាលារៀនបន្ថែម ។
- សាងសង់ទ្វារទឹក និងប្រព័ន្ធស្រោចស្រព ។
- កសាងផ្លូវគមនាគមន៏ ។

២.មន្ទីរដែនដី នគរូបនីយកម្ម និងសំណង់ គួររៀបចំនិងអនុវត្តផែនការប្រើប្រាស់ដីឱ្យបានសមស្រប ។

៣.រដ្ឋបាលជលផល គួរមានវិធានការដូចខាងក្រោម:

- ទប់ស្កាត់ការធ្វើនេសាទខុសច្បាប់ និង ការកាប់ព្រៃកោងកាង ។
- ផ្សព្វផ្សាយការចិញ្ចឹមត្រី និង ច្បាប់ជលផល ។

៤.រដ្ឋបាលព្រៃឈើ គួរមានវិធានការដូចខាងក្រោម:

- បង្កើតសហគមន៏ព្រៃឈើ ។
- ផ្សព្វផ្សាយច្បាប់ព្រៃឈើ ។

៥.មន្ទីរបរិស្ថាន គួរមានវិធានការដូចខាងក្រោម:

- ផ្សព្វផ្សាយច្បាប់បរិស្ថាន ។
- ទប់ស្កាត់ការបំពុល ។

ឃុំអណ្ដូងថ្ម ថ្ងៃ ០៩ ខែ ធ្នូ ឆ្នាំ២០០៩

មេឃុំ

វ៉ាន់ ណា

**បានឃើញ និង ពិនិត្យត្រឹមត្រូវ**

គោរពជូន ឯកឧត្តម អភិបាលនៃគណៈអភិបាលខេត្ត

និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ ខេត្តព្រះសីហនុ

"ដើម្បីមេត្តាពិនិត្យ និងសំរេច"

ព្រៃនប់ ថ្ងៃ ១៦ ខែ ធ្នូ ឆ្នាំ២០០៩

**អភិបាលនៃគណៈអភិបាលស្រុក**

**និងជាប្រធានក្រុមការងារដីរដ្ឋ**

**ស្រុកព្រៃនប់**

និត សុទ្ធី

**បានឃើញ និង ឯកភាព**

ព្រះសីហនុ ថ្ងៃ ០៤ ខែ មេសា ឆ្នាំ២០១០

**អភិបាលនៃគណៈអភិបាលខេត្ត**

**និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ**

**ខេត្តព្រះសីហនុ**

ស្បោង សារ៉ាត

# ឧបសម្ព័ន្ធ១
# ការពិពណ៌នាអំពីស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្នឃុំអណ្តូងថ្ម

## ១.ដីលំនៅដ្ឋានភូមិ

ដីលំនៅស្ថាននៅឃុំអណ្តូងថ្មចែកចេញជាពីប្រភេទ គឺ ភូមិលាយដំណាំរួមផ្សំ និង ភូមិលាយដីស្រែវស្សា (ដីថ្នាលសំណាប)

### ក. ភូមិលាយដំណាំរួមផ្សំ

ជាដីសង់ផ្ទះ និងមានដាំដំណាំរួមផ្សំជុំវិញដូចជា ដូង ស្វាយ ទឹកដោះជាដើម ហើយការសង់លំនៅដ្ឋាននេះស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៤។តាមស្ថានភាពឃុំ ប្រភេទដីសង់លំនៅស្ថានជាប្រភេទដីខាងក្រោមមានសំបកខ្យងសមុទ្រដូច្នេះការជីកអណ្តូងប្រើប្រាស់ភាគច្រើនគឺមិនអាចយកទឹកមកបរិភោគបានពីព្រោះទឹកមានជាតិជូ ដូច្នេះប្រជាពលរដ្ឋមានការលំបាកដោយគ្មានប្រភពទឹកស្អាត ។ ដោយកំណើនប្រជាពលរដ្ឋកាន់តែកើនឡើង ការសាងសង់លំនៅដ្ឋានកាន់តែច្រើនដីសំរាប់សាងសង់ជួបការខ្វះខាត ប្រជាពលរដ្ឋមួយចំនួនគ្មានដីសង់ផ្ទះបានយកដីវស្សា (ដីថ្នាល) សំរាប់សង់លំនៅដ្ឋានវិញ ។

### ខ. ភូមិលាយដីស្រែវស្សា

ដីស្រែវស្សាជាដីសំរាប់ផលិតដំណាំស្រូវក្នុងឃុំអណ្តូងថ្មមានទំហំ១៦១៧.ហិកតា។ ការដាំដំណាំស្រូវវស្សាគឺពឹងផ្អែកលើទឹកភ្លៀងទាំងស្រុង ដូច្នេះការធ្វើស្រែប្រាំងជួបប្រទះកត្តាពីរយ៉ាងជាឧបសគ្គ ទីមួយខ្វះប្រព័ន្ធស្រោចស្រព ទីពីរដោយសារមានកំរិតPHទាបនៅរដូវប្រាំងPH=4 នៅរដូវវស្សាមានកំរិតPH=5 ។ កត្តាទាំងពីខាងលើនេះហើយដែលប្រជាពលរដ្ឋនៅឃុំអណ្តូងថ្មមិនអាចធ្វើស្រែបង្កើនរដូវបានឡើយ ។

### គ. ដីចំការដំណាំ

ជាប្រភេទដីដែលស្ថិតនៅតាមបណ្តោយជើងភ្នំ ជាដីមានសណ្ឋានខ្ពស់រាប ការដាំដំណាំមិនខុសពីដីផលិតស្រូវវស្សាឡើយដោយការដាំដំណាំគឺពឹងផ្អែកតែទឹកភ្លៀងទាំងស្រុង ដូច្នេះការដាំដំណាំរួមផ្សំធ្វើបានតែក្នុងអំឡុងខែកញ្ញាដល់ខែធ្នូតែប៉ុណ្ណោះ ពីព្រោះនៅក្នុងខែនេះនៅមានទឹកភ្លៀងធ្លាក់នៅឡើយ ។ដំណាំដែលប្រជាពលរដ្ឋដាំបាន មានឪឡឹក ត្រសក់ ដំឡូងមី ដំឡូងជ្វា ពោត សណ្តែកគួរ ជាប្រភេទដំណាំមានរយៈពេលខ្លី។ ដោយកង្វះខាតនូវប្រព័ន្ធស្រោចស្រព្វនេះហើយដែលធ្វើឱ្យប្រភេទ ដីចំការនៅទំនេរជាច្រើនហិកតាមិនបានធ្វើការដាំដុះ ។

### ឃ. ដីព្រៃភ្នំ

ដីព្រៃភ្នំនៅឃុំអណ្តូងថ្មមានទំហំ ២៣៥៥១៥៣៣ ហិកតា សព្វថ្ងៃមានប្រភេទឈើកំពុងដុះឡើងវិញ មាន គគីខ្សាច់ ស្រឡៅ គគីភ្នង ចំបក ព្រីង បាយប្រវាំង និងមានសត្វព្រៃមួយចំនួនទៀតដូចជាជ្រូកព្រៃ ស្វា តូច ទន្សាយ ឈ្លូស អាញ្ចី ។ល។ សព្វថ្ងៃប្រជាពលរដ្ឋមួយចំនួនឡើងភ្នំដើម្បីរក ផ្តៅ ជ័រ វល្លិ៍ និងអនុផលព្រៃឈើ ផ្សេងៗទៀត ដើម្បី លក់ចិញ្ចឹមជីវិត។

### ង. ដីព្រៃលិចទឹក

ដីព្រៃលិចទឹកស្ថិតនៅតាមបណ្ដោយឆកវាលរេញ ជាប្រភេទដីល្បប់សមុទ្រ មានរុក្ខជាតិដុះជាច្រើនប្រភេទដូចជា កោងកាងប្រសាក់ ក្រញ៉ូង អំពូ អំពាអំពូក្រហមប្រង់ ។ល។ និងមានជីវៈចំរុះដូចជា បក្សី មច្ឆា សិប្បីសត្វ និងប្រភេទល្មូនជាដើម ។ ដោយសារមានការយកចិត្តទុកដាក់ពីរដ្ឋបាលជលផលនិងសហគមន៍នេសាទ ការការពារព្រៃលិចទឹកនេះនៅរក្សាបានទ្រង់ទ្រាយដើម ទោះបីជាមានការខូចខាតបន្តិចបន្តួចដោយសារការកាប់ដើម្បីសាងសង់លំនៅស្ថាន ធ្វើអូទូក កាប់អុសលក់ នេសាទត្រី រកងាវជាដើម ។

# ឧបសម្ព័ន្ធ២

# ស្ថានភាពនៃការគ្រប់គ្រង និងការកាន់កាប់ដីបច្ចុប្បន្ន

| ល.រ | ចំណាត់ថ្នាក់នៃការគ្រប់គ្រង និងកាន់កាប់ដី | | ក្រឡាផ្ទៃ(ហិចតា) |
|---|---|---|---|
| | តាមច្បាប់អនុញ្ញាត្តិ និងតួនាទី | តាមចំណាត់ថ្នាក់ដីរដ្ឋ និងដីឯកជន | |
| ១ | ដីព្រៃសហគមន៍ នេសាទការពារព្រៃលិចទឹក | ដីសាធារណៈ/ឯកជនរបស់រដ្ឋ | |
| ១ | ព្រៃកោងកាង | ដីសារធារណះរបស់រដ្ឋ | **១០៧,២៧** |
| ២ | ព្រៃកោងកាងទើបដាំថ្មី | ដីសារធារណះរបស់រដ្ឋ | **៣** |
| ៣ | ព្រៃឈើ | ដីសារធារណះរបស់រដ្ឋ | **២៩៣២១៧** |

ប្រភព: ទិន្នន័យGIS ប្រមូលពីមន្ទីរជំនាញពាក់ព័ន្ធជុំវិញ ជលផល ។

## ឧបសម្ព័ន្ធ៣ បញ្ហាពាក់ព័ន្ធក្នុងការប្រើប្រាស់ដី (បញ្ហា/មូលហេតុ/ដំណោះស្រាយ)

| បញ្ហា | ទីតាំងនៃបញ្ហា | មូលហេតុ | ដំណោះស្រាយ |
|---|---|---|---|
| ១ | ២ | ៣ | ៤ |
| ១- ផ្នែកហេដ្ឋារចនាសម្ព័ន្ធ | អណ្តូងថ្ម, អូរត្រាវ, ត្រពាំងស្អុយ១, ត្រពាំងស្អុយ២ និងបន្ទាយប្រីយ៍ | - មានផ្លូវលំមិនទាន់ គ្រប់គ្រាន់ | - ធ្វើផ្លូវបន្ថែម : ផ្លូវលំ, ផ្លូវគ្រោះក្រហម |
| ១.១<br>- ប្រព័ន្ធផ្លូវ<br>- ផ្លូវលំដីក្រហមទ្រុឌទ្រោម | អណ្តូងថ្ម, អូរត្រាវ, ត្រពាំងស្អុយ១, ត្រពាំងស្អុយ២ និងបន្ទាយប្រីយ៍ | ក- ដឹកហួសចំណុះ | ក.១- ជួសជុស និងថែទាំជាប្រចាំ |
| | | | ក.២- រៀបចំគណៈកម្មការថែទាំ និងថែរក្សា ព្រមទាំងបង្កើតបទបញ្ញត្តិនៃការប្រើប្រាស់ផ្លូវ |
| | | | ក.៣- ដាក់បង្គោលកំណត់ទំហំ និងទំងន់រថយន្ត និងផ្លាកសញ្ញា... |
| | | | ក.៤- ធ្វើបញ្ជីឈ្មោះអ្នកប្រើប្រាស់ផ្លូវលំ (កំណត់សេវាកម្មប្រើប្រាស់ផ្លូវ...) |
| | | ខ-ប្រភពទុនមិនគ្រប់គ្រាន់ | ក.៥- ស្វែងរកថវិកា សំរាប់ថែទាំ និងជួសជុលផ្លូវ |
| | | គ-ខ្វះប្រព័ន្ធបង្ហូរទឹកភ្លៀង | -ធ្វើលូបន្ថែម |
| ១.២- ប្រព័ន្ធស្រោចស្រព | អណ្តូងថ្ម, អូរត្រាវ, ត្រពាំងស្អុយ១, ត្រពាំងស្អុយ២ និងបន្ទាយប្រីយ៍ | ក- ខ្វះទឹកស្រោចស្រព<br>ខ- មិនអាចបញ្ចេញបញ្ចូលទឹកបាន | ក- ស្តារព្រែក និងប្រឡាយ<br>ខ- ធ្វើទ្វារទឹក |
| ១.៥- សេវាសុខភាព | អណ្តូងថ្ម, អូរត្រាវ, ត្រពាំងស្អុយ១, ត្រពាំងស្អុយ២ និងបន្ទាយប្រីយ៍ | - ខ្វះបង្គន់អនាម័យ<br>- ខ្វះប្រព័ន្ធទឹកស្អាត | - ផ្តល់បង្គន់អនាម័យបន្ថែម<br>- រៀបចំប្រព័ន្ធទឹកស្អាតតាមភូមិ |
| ១.៦- សេវាអប់រំ | ភូមិត្រពាំងស្អុយមួយ | - ខ្វះបន្ទប់រៀន | - សង់បន្ទប់រៀនបន្ថែម |
| ២_ការប្រើប្រាស់ដី | | | |

| | | | |
|---|---|---|---|
| ២.១- ដីព្រៃភ្នំថយចុះ | អណ្តូងថ្ម, អូរត្រាវ, ត្រពាំងស្អុយ១, ត្រពាំងស្អុយ២ និងបន្ទាយប្រីយ | - មកពីប្រជាពលរដ្ឋរានព្រៃយកដីលក់<br>- កាប់ឈើលក់<br>- កាប់ឈើដុតធ្យូង | - ផ្សព្វផ្សាយច្បាប់ព្រៃឈើ<br>- បង្កើតសហគមន៍ព្រៃឈើ |
| ៣- ផលិតភាពដី (កសិកម្ម) | | | |
| ៣.១- ដីខ្សោះជីជាតិ | អណ្តូងថ្ម, អូរត្រាវ, ត្រពាំងស្អុយ១, ត្រពាំងស្អុយ២ និងបន្ទាយប្រីយ | - ដុតជញ្ជ្រាំងនៅរដូវប្រាំង<br>- ការហូរច្រោះ | - ហាមធ្វើការដុតជញ្ជ្រាំងនៅរដូវប្រាំង<br>- ដាំកូនឈើឡើងវិញ |
| ៣.២- ទិន្នផលស្រូវទាប | អណ្តូងថ្ម, អូរត្រាវ, ត្រពាំងស្អុយ១, ត្រពាំងស្អុយ២ និងបន្ទាយប្រីយ | - ដីខ្វះជីជាតិ<br>- ខ្វះពូជល្អ<br>- ខ្វះបច្ចេកទេស<br>- ខ្វះការចូលរួមពីប្រជាពលរដ្ឋ<br>- ការធ្វើស្រែតែមួយរដូវ | - ជំរុញការផលិតជីធម្មជាតិ<br>- ជ្រើសរើសពូជស្រូវល្អ និងផ្តល់ខ្ពស់<br>- បើកវគ្គបណ្តុះបណ្តាលបច្ចេកដំណាំស្រូវ<br>- បំផុស និងជំរុញការចូលរួមរបស់ប្រជាពលរដ្ឋ<br>- ធ្វើស្រែបង្កើនរដូវ |
| ៤- ការគ្រប់គ្រង និងកាន់កាប់ដី | អណ្តូងថ្ម, អូរត្រាវ, ត្រពាំងស្អុយ១, ត្រពាំងស្អុយ២ និងបន្ទាយប្រីយ | - មិនទាន់មានចេញកម្មសិទ្ធិដី ចំការ<br>- ពុំមានការឯកភាពលើការកំណត់ព្រំប្រទល់អោយបានច្បាស់លាស់<br>- មិនទាន់មានការកំណត់ចំណាត់ថ្នាក់ប្រើប្រាស់ដី | - ផ្តល់ប័ណ្ណកម្មសិទ្ធិ<br>- ធ្វើការកំណត់ព្រំប្រទល់<br>-ធ្វើចំណាត់ថ្នាក់ប្រើប្រាស់ដី, ធ្វើការណែនាំនិងបំផុសគំនិតអោយប្រជាពលរដ្ឋនៅក្នុងតំបន់យល់ដឹង និងធ្វើការប្រើប្រាស់ដីអោយបានសមស្រប |
| ៥- មុខរបរ (សេដ្ឋកិច្ច) | | | |
| ៥.១- ប្រជាពលរដ្ឋមានកំរិតជីវភាពទាប | អណ្តូងថ្ម, អូរត្រាវ, ត្រពាំងស្អុយ១, ត្រពាំងស្អុយ២ | - គ្មានការងារធ្វើនៅរដូវប្រាំង<br>- ខ្វះជំនាញ | - ធ្វើស្រែបង្កើនរដូវនៅរដូវប្រាំង<br>- បើកវគ្គបណ្តុះបណ្តាលបច្ចេកទេសជំនាញ |

| | | | |
|---|---|---|---|
| | និងបន្ទាយប្រីយ | - ការប្រើប្រាស់ដីចំការមិនអស់លទ្ធភាព<br>- ខ្វះទុន<br>- ខ្វះស្រះចិញ្ចឹមត្រី និងការចិញ្ចឹមសត្វ | - បំផុសគំនិតក្នុងការដាំដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មលើដីទំនេរ<br>- ផ្តល់ទុន<br>- បើកវគ្គបណ្តុះបណ្តាលការចិញ្ចឹមត្រី និងការចិញ្ចឹមសត្វ<br>- ជំរុញការចិញ្ចឹមត្រី និងការចិញ្ចឹមមសត្វជាលក្ខណៈគ្រួសារ |
| ៩.២- ធ្វើចំណាកស្រុកនៅរដូវប្រាំង និងប្រជាពលរដ្ឋគ្មានមុខរបរ | អណ្តូងថ្ម, អូរត្រាវ, ត្រពាំងស្អុយ១, ត្រពាំងស្អុយ២ និងបន្ទាយប្រីយ | - ខ្វះការវិនិយោគពីនាយទុន និងអង្គការក្រៅតំបន់<br>- គ្មានរោងចក្រ<br>-ខ្វះបច្ចេកទេសក្នុងការដាំដំណាំឧស្សាហកម្ម | - ធ្វើការទំនាក់ទំនងទៅដល់នាយទុន និងអង្គការក្រៅតំបន់អោយមកវិនិយោគ<br>- បង្កើតរោងចក្រ (ខ្នាតតូច ឬធំ)<br>- បើកវគ្គបណ្តុះបណ្តាលក្នុងការដាំដំណាំឧស្សាហកម្ម |
| **បរិមាណត្រីថយចុះ** | អណ្តូងថ្ម, អូរត្រាវ, ត្រពាំងស្អុយ១, ត្រពាំងស្អុយ២ និងបន្ទាយប្រីយ | - ព្រៃករាក់<br>- កំណើនប្រជាពលរដ្ឋ<br>- ការប្រើប្រាស់ឧបករណ៍ខុសច្បាប់<br>- បាត់បង់ជំរកត្រី | - ស្តារព្រៃកឡើងវិញ<br>- ជំរុញការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ<br>- ផ្សព្វផ្សាយច្បាប់ជលផល<br>- ដាំព្រៃកោងកាងឡើងវិញ |

## ឧបសម្ព័ន្ធ៤ កំណត់តម្រូវការនៃការអភិវឌ្ឍន៍ គោលដៅ និងយុទ្ធសាស្ត្រ

| តម្រូវការនៃ ការអភិវឌ្ឍន៍ | ប្រភពឯកសារ | គោលដៅនៃ ការអភិវឌ្ឍន៍ | យុទ្ធសាស្ត្រនៃ ការអភិវឌ្ឍន៍ | សកម្មភាពជា អាទិភាព | លេខរៀង នៅលើផែនទី |
|---|---|---|---|---|---|
| ១ | ២ | ៣ | ៤ | ៥ | ៦ |
| ចង់បានការបើកវគ្គបណ្តុះបណ្តាលចិញ្ចឹមត្រី | ផែនការអភិវឌ្ឍន៍ប្រាំឆ្នាំរបស់ឃុំអណ្តូងថ្ម | ប្រជាពលរដ្ឋមានកំរិតយល់ដឹងមានជំនាញដើម្បីបង្កើតមុខរបរចិញ្ចឹមជីវិត មានជីវភាពគ្រប់គ្រាន់ | ផ្តល់ជំនាញដល់ ប្រជាពលរដ្ឋតាមរយៈការបើកបគ្គបណ្តុះបណ្តាល និងអនុវត្តជាក់ស្តែង | - ជីកស្រះចិញ្ចឹមត្រី តាមលក្ខណៈគ្រួសារ<br>- ស្តារដៃព្រែក និង ប្រឡាយ<br>- បើកវគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី | |
| ចង់បានស្រូវបានទិន្នផលខ្ពស់ | | ប្រជាជនមានជីវភាពធូរធារ | ជីវភាពធូរធា ការផលិតស្រូវវស្សាបានទិន្នផលខ្ពស់ | - បើកវគ្គបច្ចេកទេសដំណាំស្រូវ<br>- ផ្តល់ពូជស្រូវមានទិន្នផលខ្ពស់<br>- បើកវគ្គបណ្តុះបណ្តាលផលិតជីធម្មជាតិ | |
| ចង់ដាំដំណាំគ្រប់ប្រភេទ | | បង្កើនជីវភាពអោយប្រសើរឡើង | កាត់បន្ថយភាពក្រីក្រដោយការដាំដំណាំរួមផ្សំ | - ផ្តល់ប្រព័ន្ធស្រោចស្រព<br>- បើកវគ្គបណ្តុះបណ្តាលដាំដំណាំរួមផ្សំ<br>- ផ្តល់ពូជដំណាំគ្រប់ប្រភេទ | |
| ចង់ចិញ្ចឹមសត្វ | | បង្កើនជីវភាពអោយប្រសើរ | ចងក្រងក្រុមចិញ្ចឹមសត្វ | - ផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេសពេទ្យសត្វ និងចិញ្ចឹមសត្វ<br>- ផ្តល់វ៉ាក់សាំងការពារជំងឺសត្វ | |
| ចង់បានទឹកស្អាតសំរាប់ប្រើប្រាស់ | | - ប្រជាពលរដ្ឋមិនទាន់មានទឹកស្អាត | ស្តារប្រឡាយ និងព្រែកឡើង | - ជីកស្រះ អណ្តូង និងលូបន្ថែម | |

| | | | | | |
|---|---|---|---|---|---|
| | | សំរាប់ប្រើប្រាស់គ្រប់គ្រាន់នៅឡើយ<br><br>- មានបង្គន់អនាម័យគ្រប់គ្រួសារ | វិញ និងកសាងបន្ថែមនូវប្រព័ន្ធទឹកស្អាត | - តប្រព័ន្ធទឹកស្អាត និងកសាងប្រភពទឹកសំរាប់បំពេញតំរូវការរបស់ភូមិ ឃុំ និងស្រុក<br>- ផ្តល់បង្គន់អនាម័យតាមគ្រួសារ | |
| ចង់បានផ្លូវគ្រួសក្រហម | | ផ្តល់ភាពងាយស្រួលសំរាប់ប្រជាជនក្នុងការធ្វើដំណើរ និងដឹកជញ្ជូនផលិតផលចេញ ចូលអោយទាន់ពេលវេលា | ជួសជុលឡើងវិញនូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធនៅក្នុងមូលដ្ឋាន | - បន្តការសាងសង់ ផ្លូវគ្រួសក្រហម<br>- ដាក់លូកាត់ផ្លូវបន្ថែម | |
| ចង់បានប្រព័ន្ធស្រោចស្រព | | ប្រជាជនត្រូវការបង្កើនរដូវបង្ករបង្កើនផល | កែលំអរប្រព័ន្ធស្រោចស្រព | - ស្តារប្រឡាយចែកចាយទឹក<br>- សាងសង់ទ្វាទឹក<br>- ធ្វើសំណង់ស្ទាក់ទឹក | |
| ចង់អោយកុមារចូលរៀនបានគ្រប់គ្នា | | កុមាររៀនបានចប់យ៉ាងហោចណាស់ត្រឹមថ្នាក់ទី៩ | - ផ្សព្វផ្សាយពីសារៈសំខាន់នៃការសិក្សាទៅដល់ឳពុកម្តាយកុមារ<br>- លើកកំពស់ធនធានមនុស្ស<br>- លប់បំបាត់នូវអក្ខរភាព | - សាងសង់អាគារសិក្សា<br>- ជំរុញកុមារអោយចូលរៀនគ្រប់គ្នា<br>- ជួយឧបត្ថម្ភដល់កុមារក្រីក្រ | |
| ចង់អោយប្រជាជនយល់ដឹងពីច្បាប់បរិស្ថាន | | មានធនធានធម្មជាតិឡើងវិញនៅក្នុងភូមិ | ប្រជាជនដឹងពីអត្ថប្រយោជន៍ធនធានធម្មជាតិ និងចេះប្រើប្រាស់អោយមាននិរន្តភាព | ផ្សព្វផ្សាយច្បាប់រុក្ខា និងច្បាប់ជលផល | |

**ឧបសម្ព័ន្ធ៥ បញ្ជីគំរោង ឬសកម្មភាពសំខាន់របស់ឃុំ ក្នុងរយៈពេល ១៥ឆ្នាំ**

| ល.រ | គំរោង ឬសកម្មភាព | លទ្ធផលគ្រោង | | ផែនការប្រើប្រាស់ដីធ្លី ១៥ ឆ្នាំ | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | ចំនួន | ឯកត្តា | ៥ឆ្នាំទី១[1] | ៥ឆ្នាំទី២[2] | ៥ឆ្នាំទី៣[3] | |
| ២.៦.១ | គំរោងផ្នែកហេដ្ឋារចនាសម្ព័ន្ធ | | | | | | |
| | **២.៦.១.១. គំរោងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត** | | | | | | |
| | **១.១. ផ្លូវថ្នល់** | | | | | | |
| | ១.១.១. ផ្លូវក្រាលគ្រួសក្រហម | ១៦១០៣ | ម | ៥៣៦៧,៦៦ | ៥៣៦៧,៦៦ | ៥៣៦៧,៦៦ | |
| | **១.២. ប្រព័ន្ធស្រោចស្រព** | | | | | | |
| | ១.២.១. ប្រឡាយមេ | ៦៧០០ | ម | ៦៧០០ | | | |
| | ១.២.២. ស្តារព្រែក ចំនួន៧ខ្សែ | ២៧០០០ | ម | ៩០០០ | ៩០០០ | ៩០០០ | |
| | **១.៣. ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត** | | | | | | |
| | ១.៣.១. ចំនួន ស្ពានថ្ម | ២ | ស្ពាន | ១ | ១ | ០ | |
| | ១.៣.២. ចំនួន ទ្វារទឹក | ៣ | ទ្វាទឹក | ១ | ១ | ១ | |
| | ១.៣.៣. ចំនួនលូឆ្លងផ្លូវ | ១៥៦ | លូ | ៥២ | ៥២ | ៥២ | |
| | **២.៦.១.២. ហេដ្ឋារចនាសម្ព័ន្ធសង្គម និងសេវាកម្មផ្សេងៗ** | | | | | | |
| | ២.៦.១.២.១. សាលាមត្តេយ្យ | ៤ | បន្ទប់ | ១ | ២ | ១ | |
| | ២.៦.១.២.២. សាលាបឋមសិក្សា | ២៤ | បន្ទប់ | ០ | ៧ | ១៧ | |

[1] - ៥ឆ្នាំទី១ (២០០៨-២០១២): បញ្ចូលគំរោងទាំងអស់របស់ CDP ឆ្នាំ ២០០៨-២០១២ រួមទាំងគំរោងផ្នែកប្រើប្រាស់ដីដែលបានបង្កើតក្នុង CLUP ផងដែរ (៥ ឆ្នាំទី១)

[2] - ៥ឆ្នាំទី២ (២០១៣-២០១៧): គំរោងទាំងឡាយនៃផែនការប្រើប្រាស់ដីធ្លីឃុំ CLUP សំរាប់អោយឃុំប្រើជាមូលដ្ឋានក្នុងការកសាង CDP ៥ឆ្នាំបន្ត (៥ ឆ្នាំទី២)

[3] - ៥ឆ្នាំទី២ (២០១៨-២០២២): គំរោងទាំងឡាយនៃផែនការប្រើប្រាស់ដីធ្លីឃុំ CLUP សំរាប់អោយឃុំប្រើជាមូលដ្ឋានក្នុងការកសាង CDP ៥ឆ្នាំបន្តទៀត (៥ ឆ្នាំទី៣)

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ២.៦.១.២.៣. សាលាមធ្យមសិក្សា | ៧ | បន្ទប់ | ១ | ៦ | ០ | |
| | **២.៦.១.៣. សុខភាព និងអនាម័យ** | | | | | | |
| | ២.៦.១.៤. អណ្តូងទឹកស្អាត | ៣០០ | អណ្តូង | ១០០ | ១០០ | ១០០ | |
| ២.៦.២. | គំរោងផ្នែកប្រើប្រាស់ដីធ្លី | | | | | | |
| | **២.៦.២.១. គំរោងប្រើប្រាស់ដីតាមវិស័យធំៗ** | | | | | | |
| | ២.៦.២.១.១. ដីសហគមន៍ព្រៃឈើ | ៩៨៩.៦០ | ហិកតា | ០០ | ៥០០ | ៤៨៩.៦០ | |
| | **២.៦.២.២. គំរោងប្រើប្រាស់ដីលក្ខណៈសហគមន៍ភូមិ-ឃុំ** | | | | | | |
| | ២.៦.២.២.១. ដីភូមិ | ៣៦.២០ | ហិកតា | ០០ | ៣៦.២ | ០០ | |
| | ២.៦.២.២.២. ដីសិប្បកម្មខ្នាតតូច | ២៨.៧០ | ហិកតា | ០០ | ២៨.៧០ | ០០ | |
| | ២.៦.២.២.៣. ដីស្រែចិញ្ចឹមត្រីឬបង្គា | ១០.៦០ | ហិកតា | ០០ | ១០.៦០ | ០០ | |
| | ២.៦.២.២.៤. ដីកសិដ្ឋាន | ១៦៩.៧៥ | ហិកតា | ០០ | ១៦៩.៧៥ | ០០ | |
| | **២.៦.២.៣. គំរោងផ្នែកបង្កើនជំនាញ និងមុខរបរ** | | | | | | |
| | ២.៦.២.៣.១. វគ្គបណ្តុះបណ្តាលការចិញ្ចឹមត្រីសត្វជាលក្ខណៈគ្រួសារ | ១២០ | វគ្គ | ៤០ | ៤០ | ៤០ | |
| | ២.៦.២.៣.២. វគ្គបណ្តុះបណ្តាល អំពីការប្រើប្រាស់ដី | ៩០ | វគ្គ | ៣០ | ៣០ | ៣០ | |
| | ២.៦.២.៣.៣. វគ្គបណ្តុះបណ្តាល ការការពារធនធានធម្មជាតិ ( បរិស្ថាន,ជលផល,រុក្ខា) | ១២០ | វគ្គ | ៤០ | ៤០ | ៤០ | |
| | ២.៦.២.៣.៤. វគ្គបណ្តុះបណ្តាលបច្ចេកទេសផ្សេងៗ | ១៥០ | វគ្គ | ៥០ | ៥០ | ៥០ | |